# ការសំភាសន៍ជាលើកទី២របស់អ្នកមីង ស្រ៊ី ជៀច

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ស្រ៊ី ជៀច

## ការសង្ខេបរបស់អ្នកមីង ស្រ៊ី ជៀច

អ្នកមីង ស្រ៊ី ជៀច គាត់បានទទួលការសិក្សាត្រឹមតែថ្នាក់ទី១តែប៉ុណ្ណោះ ដោយសារតែជីវភាពគាត់ក៏បានបញ្ឈប់ការសិក្សារបស់គាត់អ្នកមីងអត់ចេះអក្សរទេ!! អ្នកមីងបានរៀបការជាមួយស្វាមីជនជាតិចិនហើយមានកូនស្រីម្នាក់ គាត់បានជួបគ្នាពេលអ្នកមីងទៅរើសហុងអំបោះ!! ហើយស្វាមីគាត់ក៏មានប្រពន្ធនៅចិនផងដែរ ហើយអ្នកមីងបានប្រាប់ថាពេលដល់វេលាកំនត់ប្តីនឹងត្រលប់ទៅស្រុកចិនវិញ។ ហើយមីងបានកើតទាន់ពេលសង្គ្រាមប៉ុលពត ហើយបាននៅក្នុងកងកុមារ ។ ជីវិតអ្នកមីងគាត់បានប្រកបរបរធ្វើស្រែនឹងចំការនិងធ្វើការរោចក្រកាត់ដេរ តែពេលឥឡូវគាត់បានផ្លាស់ប្តូរជាអ្នករកស៊ីលក់ដូរវិញ សព្វថ្ងៃគាត់រស់នៅជាមួយឪពុកម្តាយបងប្អូននឹងកូន។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីង ដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងជាលើកទី២ នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនៅក្នុងថ្ងៃនេះ ពួកយើងសំភាសន៍នៅក្នុងខែ មេសា ឆ្នាំ២០១៨ ការសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិកោះគរ ឃុំ រកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ប្រទេស កម្ពុជា អ៊ីចឹងពេលមុនញ៉ុមបានសំភាសន៍អ្នកមីងកាលពេលមុនរួចម្តងអំពីជីវប្រវត្តិរបស់ខ្លួនឯងក៏ដូចជាក្រុមគ្រួសារនឹងបងប្អូនផងដែរ អ៊ីចឹងចង់អោយអ្នកមីងនិយាយប្រាប់ខ្លះៗទៀតអំពីការសិក្សានឹងអំពីស្វាមីទៀតនឹងប្រវត្តិរបស់អ្នកមីង តាំងពីតូចរហូតដល់ធំមក អ៊ីចឹងអ្នកមីងសូមប្រាប់ឈ្មោះពេញម្តងទៀត!!

ខៈ ខ្ញុំបើ សរសេរក្នុងសៀវភៅមិនដឹងគេដាក់ម៉េចទេ ព្រោះញ៉ុមអត់ចេះអក្សរហាំ!!

កៈ ចាំ!!

ខ៖  ប៉ុន្តែញ៉ុមរាល់ថ្ងៃឈ្មោះមីង ជ្រៀច មីងជ្រៀង!!ហៅតែ

ក៖  ស្រី ជ្រៀច?

ខ៖  ជ្រៀច ជ្រៀច រាល់ថ្ងៃហ្នឹង!!

ក៖៖ ចាំហ្នឹងហើយ !!

ខ៖  ខ្លះគេហៅមីងជ្រៀច មីងជ្រៀចអ៊ីចឹងទៅ ខ្លះគេហៅបងជ្រៀច បងជ្រៀចអ៊ីចឹងទៅ!!ហ្នឹង!!

ក៖  មីងមីងដែលមានឈ្មោះហៅខាងក្រៅអីអត់?

ខ៖   ឈ្មោះក្រៅមួយទៀតហោ?

ក៖  ចាំ !!

ខ៖  ឈ្មោះហុង!!

ក៖  ក្រុង?

ខ៖  ហុង។

ក៖  ហុង !!

ខ៖ ចាំ !! អាកុងញ៉ុមហៅញ៉ុមតែហុង ហុងឈ្មោះខាងក្រៅហ្នឹង!!

ក៖  ហើយម៉េចហៅអ៊ិចឹងវិញ?

ខ៖  ដឹងអីគាត់!!

ក៖  យូរនៅ?

ខ៖  ប្រហែល៤ ៥ឆ្នាំហ្នឹង។

ក៖  ហ្ញូទឹមតែនេះហ្នឹងហី?

ខ៖ ចាំ!!

កៈ តែទៅជាប្តីជាអ្នកដាក់អោយទេហេ?

ខៈ  តែនៅក្នុងបញ្ជីជាតិដាក់ជ្រៀចទេ!

កៈ ចាំ!!

ខៈ  តែនៅក្នុងបញ្ជីជាតិហ្នឹង។

កៈ  តែឈ្មោះខាងក្រៅហ្នឹងប្តីដាក់អោយទេណោះ?

ខៈ ចាំ!!

កៈ  ហៅអិចឹងទៅណោះ?

ខៈ ចាំ!!

កៈ ចាំ!!

ខៈ  គ្រាន់តែថាអញ្ចេកជូនប្រពន្ធគាត់នៅណោះ!!

កៈ ហ៊ឺះ!!

ខៈ អញ្ចឹងដែរ ឈ្មោះ
គាត់ហៅញ៉ុមអីចឹងគាត់ថាគាត់ពិបាកហៅឈ្មោះញ៉ុមណាស់អិចឹងគាំតហៅឈ្មោះញ៉ុមតែអញ្ចឹង ។

កៈ  ចាំអីចឹងគាត់ដូរឈ្មោះអោយអញ្ចឹងទៅ!!

ខៈ  ដូរឈ្មោះហ្នឹងអោយ!!

កៈ ចាំ!!អីចឹងអ្នកមីងសំរាប់ចូលដល់ការសិក្សាសិន ចាំតិចទៀតចាំចូលដល់ប្តីមើលម៉េចដែរ!!
មីងរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខៈ  ញ៉ុមទី១។

កៈ  បានតែទី១ទេអីចឹងហេ?

ខ៖ ចាំ!!

ក៖ មីងរៀននៅសាលាបឋមសិក្សាណាវិញ?

ខ៖ ឈូងលៀបហ្នឹង!!

ក៖ ចាំ!! ហើយនិយាយថាមូលហេតុអីបានឈប់រៀន?

ខ៖ មូលហេតុទី១យើងពិបាកវេទនាហើយយើងអត់ចេះផង!!

ក៖ ចាំ!!

ខ៖ ណាមួយយើងរកចេះម៉េចបើយើងគ្រួសារខ្វះខាតអីចឹង
ហើយអាលែងតែរៀនម៉េចបានអីហូបអញ្ចឹង!!

ក៖ ចាំហើយឮមិញបងអីវ៉ាន់និយាយម៉េចថា
ទៅរៀនសំរាននៅហ្នឹងទៀតហោ?រៀនៗឯក់មីងហោ?

ខ៖ ចុះកូនក្មេងយើងមិនដេក។

ក៖ រៀនៗឯក់អញ្ចឹងទៅមីងណេះ?

ខ៖ ចាំរៀនៗងោកអីចឹងទៅ!!

ក៖ ហ៊ឺ!!

ខ៖ ហើយដូចថាអើយ
រៀនអើយបើណាមួយយើងវារៀនអត់ចេះផងយើងគិតតែរឿងអត់ស៊ីមានស៊ីជំនាន់ហ្នឹងហ្នំ!!
អត់អីស៊ីរៀនក្រោយខ្វះមុខរៀនមុខខ្វះក្រោយហ្នឹង!!

ក៖ ហ៊ឺ!!

ខ៖ រៀនអត់ទាំងចេះផងហ្នឹង ហើយឥលូវក៏មើលអត់ដាច់ដែរ!

ក៖ តែពេលនៅរៀនថ្នាក់ទី១ហ្នឹងអានបាន ក ខ ហ្នឹងចេះច្រើនណាស់មីងណេះ?

ខ៖  ក ខ ង ហ្នឹង តែទន្ទេញ ទន្ទេញចាំតែមាត់ហ្នឹងអោយមើលអក្សរណាក៏អត់ចេះដែរ!!

ក៖ អ៊ិចឹងទន្ទេញចាំតែមាត់ទេមីងហេ?

ខ៖  ទន្ទេញចាំតែមាត់ហ្នឹង!!

ក៎៖
មីងដូចនៅពេលពីក្មេងហ៎ាក្តីស្រម៉ៃអ្នកមីងចង់ធ្វើអីគេដែរពេលទោះបីថាមីងអត់បានរៀនដល់អីណាដែលមានក្តីស្រម៉ៃអីអត់?ថាធំឡើងចង់ធ្វើអីមួយលក់ដូរ គោលគំណិតអីអញ្ចឹងហ៎ា?

ខ៖  ដូចថាចង់ ដូចថាអត់ចង់ដូចថាពីទូចៗហា ដូចថាខំតែរកអោយតែបានតែហូបម៉ងរាល់ថ្ងៃកាលនៅពីទូចហ៎ា!!

ក៖  ចុះអត់មានគិតអីទេហេ?

ខ៖  ដូច ដូចអត់ទាន់ចេះគិតហ៎ាទូចៗហ៎ា!!
គិតថាអញ្ចេកអោយតែខំរកអោយបានទៅកុំអោយតែជំពាក់គេថាអោយបានជីវភាពក្នុងផ្ទះអោយបានគ្រប់គ្រាន់ទៅវាអត់បានគ្រប់គ្រាន់ទៀត កាលនៅទូចៗគិតអញ្ចឹងណាស់។

ក៖ ហ៊ឺៗ!!

ខ៖ ហើយចុះអត់មានគិតថាចង់មានចង់បានណាដូចឥឡូវទេ អត់ទេ អត់ទេ!!

ក៖ ចា៎!!

ខ៖ រាល់ថ្ងៃនេះក៏ដោយគិតថាកុំអោយតែជំពាក់គេបាន រាល់ថ្ងៃនេះ គិតអញ្ចឹងណាស់!!

ក៖ ហ៊ឺៗ!!

ខ៖  អោយខំរកកុំអោយតែរាល់ថ្ងៃនេះកុំអោយតែថាជំពាក់គេរាល់ថ្ងៃ!!

ក៖  ញ៉ុមចាំមើលញ៉ុមសង្ឃឹមថាដល់ពេលញ៉ូម!!

ខ៖  ហើយនឹកឃើញថាដល់ពេលអញ្ចេកដូចថាអើយយើងអើរអើយឃើញឆ្ងាយយើងឃើញជិតៗទៅណាស់ គ្រាន់តែថាយើងមិនរកស៊ីអីធំដុំណាដូចគេ

គ្រាន់តែថាយើងលក់អញ្ចឹងកំប៉ែកំប៉ុកអញ្ចឹងដូចថា
អានេះយើងនិយាយអោយខ្លីទៅណាស់ដូចថាតាមកុំអោយតែជំពាក់គេទៅ
ដូចថាបានអោយតែបានមួយគ្រប់គ្រាន់ មួយគ្រប់គ្រាន់ទៅ
អោយគ្រប់គ្រាន់រាល់ថ្ងៃអីចឹតងទៅណាស់!!!

ក៖  ទប់ទល់ ទប់ទល់ អីចឹងទៅមីងណោះ?

ខ៖  ទប់ទល់ ទប់ទល់ ទុកអោយតែកូនរៀនទៅណាស់ៗ!

ក៖ ហ៊ី!!

ខ៖ នឹកឃើញថាអញ្ចេកឪវាទៅស្រុកទៅយើងខំរកស៊ីចិញ្ចឹមកូនទៅណាស់
នឹកឃើញអញ្ចឹងណាស់រាល់ថ្ងៃណាស់គិតថាអញ្ចឹង!!

ក៖  អញ្ចឹងរាល់ថ្ងៃគិតថាប្តីនឹងទៅស្រុកទៅចោលហើយហោ?

ខ៖  តែគាត់ទៅស្រុកគាត់ទៅហើយ !! គាត់ថាអញ្ចេក គាត់មក គាត់មកធ្វើប៉ាស់ស្ពរ័២០០៩
២០០៩ តែប៉ាស់ស្ព័រគាត់១០ឆ្នាំហាំ !!
តែឥឡូវ២០១៨ហើយណាស់អីចឹងនៅឆ្នាំក្រោយទៀតហាំ គាត់និយាយហី
នៅឆ្នាំក្រោយមួយឆ្នាំទៀត
គាត់ធ្វើឆ្នាំក្រោយមួយឆ្នាំទៀត២០២០បានគាត់ទៅណាស់!!ហើយញ៉ុមគិតថាអញ្ចេក
អើយពីបាកណាស់ពេលគាត់ទៅអញ្ចឹងណាស់
គាត់នៅហ្នឹងគាត់នឹកឃើញចេះគាត់ជួយកូនខ្លះៗទៅណាស់!!ប៉ុន្តែតែគាត់ទៅបាត់គាត់ទៅហើ
យ!គាត់ទៅ!

ក៖ អើយមីងម៉េចទៅជ្រើសរើសផ្លូវមួយហ្នឹងវិញម៉េចទេ??

ខ៖  ញ៉ុមនឹកឃើញថាអញ្ចេក នឹកឃើញអញ្ចេក នឹកឃើញថាអញ្ចេកខំរករាល់ថ្ងៃ
គាត់ទៅទៅទៅណាស់។

ក៖ ហ៊ី!!

ខ៖
តែយើងនឹកឃើញថាអោយតែបានកូនស៊ីអោយតែបានកូនរៀនអីអញ្ចឹងទៅណាស់!!អោយបានគ្រប់គ្រាន់អីអញ្ចឹងទៅណាស់!!

ក៖ ចាំ!!

ខ៖ កុំអោយតែជំពាក់គេ នឹកឃើញតែប៉ុណ្ណឹងទេណាស់រាល់ថ្ងៃហាំ!!

ក៖ ហ៊ឺ!!

ខ៖
អត់ចង់អីណាទៅធ្វើអ្នកមានអ្នកក្រអីណាទេ!!បើយើងញ៉ុមនឹកឃើញអញ្ចឹងហាំរាល់ថ្ងៃហ្នឹងហា!!

ក៖ ហ៊ឺ!!
នឹកឃើញថាអោយកូនអោយបានគ្រប់គ្រាន់អិចឹងហើយញ៉ុមអត់ចិត្តហើយរាល់ថ្ងៃហ្នឹង!!

ក៖ ឥឡូវប្ដីអ្នកមីងគាត់ឈ្មោះអីគេ?

ខ៖ ស៊ី សាង។

ក៖ ស៊ី សាង?

ខ៖ ចាំស៊ី សាង!!

ក៖ ឥឡូវគាត់អាយុប៉ុន្មានហើយ?

ខ៖ ឥឡូវអាយុគាត់៦០ជាងហើយ។

ក៖ ហ្ហំ!!

ខ៖ ហើយសេចក្ដី
ដូចហ្អែងសួរញ៉ុមអញ្ចេកថាអត់មានសេចក្ដីស្រម៉ៃថាអញ្ចឹងអីអញ្ចឹងទៅណាស់!

ក៖ ហ៊ឺ!!

ខ៖ ខ្ញុំអញ្ចេកនឹកឃើញថាសេចក្ដីដែលខ្ញុំគិតហ៊ីនឹកឃើញថាអញញអើយ
ចេះតែគិតក្នុងចិត្តហា៎ ថាអញអើយ
អាកុងទៅស្រុកទៅប្ដីទៅស្រុកទៅនឹកឃើញតែរកខំប្រឹងអោយតែកូនបានហូបគ្រប់គ្រាន់កុំអោយតែជំពាក់គេហើយអោយតែកូនរៀន។

ក៖ ហ៊ឺ!!

ខ៖
ហើយនឹកឃើញណាមួយនឹកឃើញខ្លាចថាអត់មានអីអោយកូនរៀនអញ្ចឹងណាស់!!!!អញ្ចឹងទៅយើងត្រូវខំរករាល់ថ្ងៃហ្នឹងហា៎!!!ហើយណាមួយអត់ធ្វើ អត់ធ្វើការទៀតឥឡូវ!!

ក៖ ហ៊ឺ!!

ខ៖ ហើយទោះតែចូលធ្វើការ៦ខែគេផ្ដាច់យើងហ្នឹង បើគេយកយើងយក
បើគេអត់យកយើងវិញ!!

ក៖  បញ្ឈប់ចោល?

ខ៖  គេបញ្ឈប់ចោលទៅ!!

ក៖  ចំ!!ពួករោងចក្រហ្នឹងចេះម្ល៉េះ!!

ខ៖  អឺចឹងបានថាឥឡូវយើងឈប់យើងនៅលក់ទឹកលក់អីអញ្ចឹងទៅណាស់!!ហើយហ្នឹង
ហើយអញ្ចឹងបានថាអញ្ចេក
បើយើងមានសេចក្ដីស្រម៉ៃម៉េចបើយើងអត់មានទីសង្ឃឹមផងហ្នឹងរាល់ថ្ងៃនឹកឃើញតែខំរកអោយកូនស៊ីអោយកូនរៀនអីអញ្ចឹងទៅណាស់!!

ក៖ ហ៊ឺៗ!!

ខ៖ ហ្នឹង ទោះយើងទៅស្រម៉ៃអីទោះយើងអត់ទៅចេញអីណាអីរាប់ពាន់រាប់ម៉ឺនដែរ
អញ្ចឹងកុំស្រម៉ៃ!!

ក៖ អូខេ ឥឡូវមីងដំបូងម៉េចបាន!!

ខ៖  ថាវេទនាណាស់។

ក៖
មីងឥឡូវនិយាយប្រវត្តិស្នេហាអ្នកមីងជាមួយប្ដីតិចមើលម៉េចបានជួបគាត់គាត់ជនជាតិចិននេះហិ?

ខ៖  ចំមើលហា៎!!

ក៖ ហ៊ឺ!!

ខ៖ គោលបំណងរបស់ញ៉ុមអត់យកប្ដីទេចិន មុនស្ដីញ៉ុមញ៉ុមអត់យកទេ ប្ដីហា៎ ចិនញ៉ុមអត់សូវចូលចិត្តទេដល់ពេលនេះកុំមុយនីស!!

ក៖ ចា៎!!

ខ៖ ញ៉ុមនិយាយអ៊ីចឹងម៉ងយកទៅ និយយាខុសឬក៏ត្រូវទេខ្ញុំហ្ន៎!!

ក៖  ហ្នឹងហើយចិនកាន់លទ្ធិកុំមុយនីសហ្នឹង!!

ខ៖  ហ្នឹងញ៉ុមភ័យណាស់ញ៉ុមនិយាយអ៊ិចឹង ញ៉ុមថាញ៉ុមអត់យកទេ!!

ក៖ ចា៎!!

ខ៖ ពេលមុនចិនតែវ៉ាន់ស្ដីញ៉ុមពេលមុនញ៉ុមអត់យកផង៨០០០ដុល្លារ ម៉ែញ៉ុមថាអញ្ចេកហ៊ីង៉ែង គេយកលុយមកអោយដល់ផ្ទះហើយង៉ែងអត់យក!!
ញ៉ុមអត់យកទេព្រោះអីចិនក្រវែកក្រវក់ច្រើនណាស់!!វាគំនិតខូចហា៎!!

ក៖  ហ៊ឺ!! តាំងពេលអាយុប៉ុន្មានពេលហ្នឹង?

ខ៖  ខ្ញុំអាយុ២៥ !!

ក៖ ហ្ន៎!!

ខ៖ ខ្ញុំក្រមុំចាស់ហើយ!! ២៥ហ្នឹងហា៎ខ្ញុំក្រមុំចាស់ហើយ!!

ក៖ អើយចាស់ណាទេ ញ៉ុម២៧ហើយញ៉ុមមិនទាន់ផងនេះ!!

ខ៖  ចាំមើលញ៉ុមនិយាយដល់ពេលហើយទៅញ៉ុមមិនយកទៅ
ដល់ពេលហើយទៅគេចូលស្ដីញ៉ុមហាហើយអាកូវហ្នឹងគេជំនូននៅផ្ទះបងជីដូនមួយញ៉ុមនៅ
នោះ!!

ក៖  ទៅស្ដីនៅនោះវិញហ្នឹងអញ្ចឹង?

ខ៖ ចាំ!!ជីទូតមួយនេះនៅផ្ទះជិតនេះហ៎!! ដល់ពេលហើយទៅញ៉ុមថាហ៊ុអត់យកទេ!!

ក៖ ហ៊ី!!

ខ៖  ដល់ពេលហើយទៅញ៉ុមថាយកតែពីមុនក្រោយខ្ទងញ៉ុមអត់យក
យកម៉េចចុះបើរវៗវាយកយើងទៅលក់ទៅ!!

ក៖ ហ៊ី!!

ខ៖ ចិនអត់បានទេ!!ដល់ពេលហើយទៅញ៉ុមក៏ស្អែកឡើងខ្ញុំអើអើរ
អើអើរពីមុនម៉ែប៉ាញ៉ុមអញ្ចឹងទៅ ប៉ាញ៉ុមខឹងម៉ែញ៉ុមខឹងទៀត
ហើយបងប្អូនញ៉ុមខឹងញ៉ុមណាស់!!

ក៖ ហ៊ី!!

ខ៖ ង៉ែងចិនស្ដីអត់យកទេ ង៉ែងស៊ីទៅស៊ីព្រុសកន្ទេលទៅស៊ីទៅ និយាយអញ្ចឹង!!
លុយដែលកំលាំងញើសឈាមគេញ៉ុមអត់ចង់បានទេ
ញ៉ុមកំលាំងញើសឈាមខ្លួនឯងបានញ៉ុមចូលចិត្ត ញ៉ុមចង់បានហ៎!!

ក៖ ហ៊ី!!

ខ៖  ញ៉ុមលក់ទឹកមួយថ្ងៃបាន កំលាំងញ៉ុមរាល់ថ្ងៃរក ដូចថាវាសមនឹងបានសមស្របហ៎!!
ឪញ៉ុមបន្ទោសអើយបន្ទោស ថាហ្អែងគេមកស្ដី!!

ក៖  តែឥលូវទៅដល់ណាហើយ?

ខ៖  អាចិនតែវ៉ាន់ហ្នឹងទៅបាត់ហើយ ហើយទៅធ្វើចិញ្ចៀនអោយញ៉ុម២ជីទៀត !!

ក៖ ហ៊ីៗ!!

ខ៖ ចិញ្ចៀនមាសឡើងក្រហមរងៀលហ្នឹង!!
ដល់ពេលហើយទៅញុំមថាយកនៅមុខហ្នឹងតែដល់ពេលហើយក្រោយទៅអត់យកវិញញុំមខ្លាចយកញុំមទៅលក់!!

ក៖ ហ៊ឺ!!

ខ៖ ចិនមិនបានទេ!!

ក៖ តែគាត់រោងចក្រដែរហោ?

ខ៖ អត់ទេ ចិនហ្នឹងថៅកែលក់ឡានទៀត
ប្អូនគេហ្នឹងបងគេហ្នឹងថៅកែលក់ឡានហើយគេហ្នឹងថៅកែលក់ឡានជាមួយបងប្អូនដែរ
តែគេណោះគេមានជាងហាំ !!តែញុំម ញុំមអត់យកទេព្រោះអីមានអីអញ្ចឹងញុំមអត់ចូលចិត្តទេ
មានដូចថា មានដូចអត់ស្វរសមស្របអញ្ចឹងណាស់!!ក៖ ចាំ!!

ខ៖ ខ្លាច វរ វរហ្នឹងយកយើងទៅលក់ទៅ!!

ក៖ ចាំហ្នឹងហើយភ័យខ្លួន!!

ខ៖ ៨០០០ដុល្លារញុំមអតចង់បានលលុយទេ ញុំមអត់ចង់បាន ញុំម
ញុំមអត់ចេះអក្សរមែនតែញុំមគិតណាស់!!

ក៖ ហ៊ឺ!!

ខ៖ ញុំមថាហ៊ឺញុំមខ្ជិលណាស់!!ម៉ែញុំមមកខឹង ខឹងញុំមទឹមតែឥឡូវទេបានអន់ខឹង
ដល់ហើយទទួលនេះចិនប្តីញុំមរាល់ថ្ងៃនេះស្តី ឥឡូវហ្នឹង! ញុំមរើសហុងអំបោះ ទៅរើស
ទៅរើសរាល់ថ្ងៃញុំមអត់ដែលបានដេកបានពួនទេ
ញុំមនឹកឃើញថាយកមកអោយនៅក្នុងក្រុមគ្រួសារហាំរើសហុងអំបោះហ្នឹងហាំ!!

ក៖ ហ៊ឺ!!

ខ៖ ហើយញុំមធ្វើការបណ្តើរ គេគេដេកស្កិញៗញុំមអត់ដែលដេកថ្ងៃទេ រើសហុងអំបោះ
ញុំមហូបបាយហើយលែងមាត់អត់ទាន់ទេញុំមទៅរើសហុងអំបោះញុំមប្រាប់ហ្អែង
ញុំមអត់ដែលបានដេកថ្ងៃទេរើសហុងអំបោះ ដល់ពេលហើយទៅទទួលជួបអាកុង ជួបអាកុង

អាកុងចេះតែលួចលបមើលខ្ញុំអើយ លួចលបមើល!! លបមើលខ្ញុំរាល់ថ្ងៃ
ចុះម៉េចអញ្ចឹងម្នាក់ហ្នឹងចេះតែលួចលបមើលខ្ញុំអញ្ចឹង គាត់ស្រលាញ់ញ៉ុមហាំ
គាត់លបមើលអើយលបមើលខ្ញុំ
ទទួលបានញ៉ុមទៅរើសហ្នឹងហាំមួយឆ្នាំពីរឆ្នាំហាំទៅរើសហុងអំបោះហ្នឹងហាំ!!

កៈ អញ្ចឹងលួចស្រលាញ់យូរហើយហ្នឹង?

ខៈ  ចាំលួចស្រលាញ់យូរហើយ ដល់ពេលហើយញ៉ុមអត់ដឹងខ្លួនទេ
ដល់ពេលហើយទៅរើសហុងអំបោះដល់ពេលហើយទទួលហើយទៅហ៊ីអត់ដែលបានដេកថ្ងៃ
ហ្នឹងគេទេស្បោងខ្មៅមួយប៉ុនៗហ្នឹងហ៎ទៅរើសបានមៈយហុងមួយហុងទៅរើសហើយជាន់ៗ!!
គាត់ឃើញខ្ញុំ!!

កៈ  ហើយយកមកធ្វើអីគេហុងអំបោះ?

ខៈ  យកមកដុត រើសបាន៤ ៥ បាវ៦បាវហ្នំ!!

កៈ  ថង់ធំហោ?

ខៈ  ណោះមួយស្បោងសរលើកគ្នា៣ ៤នាក់អត់ចង់រួចទេណាស់!

កៈ ហើយយកមកដុតស្អីគេ?

ខៈ  ចាំមើលអញ្ចេកមួយថ្ងៃរើសបានបន្តិច មួយថ្ងៃរើសបានបន្តិច
មួយស្បោងតិចប៉ុនៗហ្នឹងហ៎!!យកមក យកមករាល់តែថ្ងៃ
ដល់ពេលហើយទៅញ៉ុមរៀបមកដល់ផ្ទះញ៉ុមរៀបទៀត
រៀបដាក់ញាត់បាវហ្នឹងដាក់ឡើងណែនហ្នឹងពែសៗលើកគ្នា២ ៣នាក់ឡើងញរែសក់ក្បាល!!

កៈ ហ៊ីៗ!!

ខៈ លើកអត់ចង់រួចទេ យកមកទុកសំរាប់ម៉ែលក់កាហ្វេដុតណាស់
នឹកឃើញជួយគ្រួសារកុំអោយទិញគេអស់លុយ!!

កៈ ហ្នំ!!

ខ៖ ញ៉ុមគិតឃើញអញ្ចឹងទេ
គេគេចោលទេ!!ក្នុងរោងចក្រហ្នឹងគេចោលហើយគេថាអោយរើសទៅ
គេគេអត់ចង់បានគេអត់រើសទេ គេថាគេខ្ជិលណាស់ គេដេកសិន។

ក៖ ចាំ!!

ខ៖ ពីព្រោះយើងអត់ណាស់!!

ក៖ ចាំ!!

ខ៖ ដល់ហើយអញ្ចឹងទៅអាកុងឃើញញ៉ុមហ្នឹងទៅស្រលាញ់
ស្រលាញ់ប្រាប់អាមួយហ្នឹងថាអញ្ចេកហ៊ីគាត់ស្រលាញ់បងឯងចង់យកអត់?ហ៊ីញ៉ុមអត់យកទេ
ញ៉ុមអត់យកទេចិន ញ៉ុមអត់យកទេ!!

ក៖ ហ៊ីៗ!!

ខ៖ ចិនកុំមុយនីស ញ៉ុមអត់ចូលចិត្តទេញ៉ុមនឹកឃើញអញ្ចឹងណាស់
ដល់ពេលទទួលញ៉ូមមកនិយាយប្រាប់ម៉ែខ្ញុំ!!

ក៖ ហ៊ីៗ!!ខ៖
ដល់ពេលម៉ែញ៉ុមនិយាយថាអញ្ចេកយកទៅយកទៅង៉ែងចិនស្តីពីរដងហើយ!!ដល់ហើយស្រាប់តែទទួល!

ក៖ ឆ្នាក់តែរឿងចិនហ្នឹងម៉ងមីងហេ?

ខ៖ ចាំ!! ញ៉ុមមិនដឹងអាម៉េច មិនដឹងអាម៉េចដល់ពេលហើយទៅ
ហ្នឹងដល់ពេលហើយទៅប្រាប់ចាន់ថាញ៉ុមនៅថៃ គេទៅប្រាប់ទៀត
ថាហ៊ីចាន់ថាអើយចិនចង់បានបងណាស់ឥឡូវអញមិនដឹងម៉េចទេនេះ អត់ចង់យកទេ!!
ហោយកទៅ តែចាស់ទៅយើងអត់មានមួយរៀលហិ អត់មាសអត់មានប្រាក់អីហ្នឹងគេ
អត់លុយរាប់ពាន់រាប់ម៉ឺនដូចគេទេណោះ អត់មានដីទេណោះ យកទៅ
យកទៅសំរាប់ចាស់ឡើងមើលយើងហិ។

ក៖ តែដល់ពេលអ្នកមីងចាន់ថាអត់ព្រមយកប្តីដែរ?

ខ៖  ចាំ!!ហ្នឹង!! ចាំមើលញុំមនិយាយសិន ដល់ហើយស្រាប់តែថាយកទៅយកទៅ
ហើយដល់ពេលញុំមទៅបងប្អូនញុំមនៅភ្នំពេញគេថាមីអូនអើយ
ដូចថាគេអានិតស្រលាញ់ញុំមហា៎ គេឃើញញុំមស្លូត!!

ក៖ ចាំ!!

ខ៖  ហើយគេអានិតខ្ញុំរកស៊ីចិញ្ចឹមម៉ែ កូនទាំងអស់គឺញុំមហ្នឹងជាងគេ ខំជួយម៉ែ
ខំជាងគេដល់ពេលហើយទៅញុំមម៉ែញុំមចេះតែនិយាយបងប្អូនញុំមអាប្រុសហ្នឹងនិយាយថា
យកទៅយកទៅថាអញ្ចឹង ចាស់ឡើងអត់មានអ្នកណាមើលទេ!!!
អត់មានអ្នកណាមើលខ្លួនឯងទេ!!

ក៖  ចុះគេអាលែងមើលរវល់គ្រួសារគេដែរអ៊ីចឹងទៅណាស់!!

ខ៖  គិតគូរគ្រួសារគេដែរទៅណាស់!!គេរវល់គិតពីផលប្រយោជន៍គេគ្រួសារគេ អញ្ចឹងហា៎
យើងរកស៊ីចិញ្ចឹមម្តាយឪពុកយូរហើយ ពិបាកវេទនាណាស់អូនរកជួយម៉ែញុំមហា៎!!

ក៖ ហ៊ឺៗ!!

ខ៖ ញុំមពិបាក។

ក៖ ចាំ!!

ខ៖ ដល់ពេលហើយទៅ
ដល់ពេលទៅក៏ខ្ញុំយកទៅតាមបងប្អូនអ្នកនៅរោងចក្រអីយកទៅជ្រៀចអើយហ្អែងយកទៅ!!

ក៖  ហើយគាត់ធ្វើការអីគេនៅក្នុងរោងចក្រហ្នឹង?

ខ៖  ឡ ដល់ពេលហើយយកទៅ យកទៅ
ដល់ពេលហើយគាត់ប្រាប់ញុំមថាអញ្ចេកគាត់មានតែ២៥០ទេយកបានយកទៅយកមិនបានក៏
អត់យកទៅ!!ហើយញុំមថាអញ្ចេកសេចក្តីលុយ សេចក្តីស្រលាញ់ញុំម
ញុំមអ់តស្រលាញ់រឿងលុយទេ
ញុំមស្រលាញ់អោយតែថាអោយតែបានកូនអោយតែថៃមើលយើងចាស់មើលគ្នាទៅវិញទៅម
ក!!

កៈ ចាំ!!អ៊ីចឹងគាត់អត់មែនមេការមេអីទេហេ?

ខៈ អត់មេទេ!! គាត់ចាំមើលថាដូចពួកដែលថាពួកអើយកូនចៅអីនៅក្នុងហ្នឹងហាំ ចាំមើលអោយគេដឹកអុសដឹកអីយកមកបោះចូលឡអញ្ចឹងទៅណាស់!!

កៈ ហ៊ឺ!!

ខៈ តែអាកុងញ៉ុមស្លូតណាស់ គេលេងសើចជាមួយគាត់គេលេងសើចជាមួយសុទ្ធតែដូចថាកាច់ដៃកាច់ជើងគេលេងដូចថាគេលេងសើចហាំ!!

កៈ ចាំ!!

ខៈ អាកុងញ៉ុមហ្នឹងស្លូតជាងគេ។

កៈ ចាំ!!រោងចក្រអីគេវិញមីង?

ខៈ រោងចក្រសិត្ស តែក្រៅពីហ្នឹងសុទ្ធតែកាចៗ។

កៈ ខោអាវតើហី?

ខៈ ក្រៅពីហ្នឹងសុទ្ធតែកាចៗ ។

កៈ រោងចក្រខោអាវមីងណោះ?

ខៈ រោងចក្រខោអាវ។

កៈ តែម៉េចដាក់អុសចូលឡវិញធ្វើអីគេវិញ។

ខៈ អាហ្នឹងគេដុតឡ គេដុតឡ គេអ៊ុតហាំ!!

កៈ ហ្វាំៗ!!

ខៈ ហើយគាត់ហ្នឹងគាត់ស៊ីឈ្នួលគេទេ គាត់ស៊ីឈ្នួលគេទេ ដល់ពេលហើយរៀបជាមួយញ៉ុមទៅ ។

ក៖ ហ៊ឺ!!

ខ៖ ហើយញ៉ុមរៀបទំរាំញ៉ុមរៀប២
៣ខែដែរទំរាំញ៉ុមរៀបហ្នឹងហាំ!!ញ៉ុមប្រាប់ថាអញ្ចេកហោញ៉ុមមិនយកទេចិន
ចិនអត់យកទៅស្អប់ណាស់ អត់ចូលចិត្តទេចិន។

ក៖  គាត់អត់សួរមានប៉ុន្មានដែរមីងណោះ?

ខ៖  អត់សួរមានប៉ុន្មានទេ តែគ្រាន់តែបានប្រាក់ខែតិចតួចៗអញ្ចឹងទៅ
អោយញ៉ុមក៏អោយទៅមិនអោយក៏ហែទៅញ៉ុមមិនថាអី!

ក៖  អញ្ចឹងទៀត!!

ខ៖  ដូចថាគាត់ផ្ញើរទៅកូនរៀនអញ្ចឹងហាំ!!

ក៖ ហ៊ឺៗ!!

ខ៖ បើកមកមិនមែនរាប់លុយអោយយើងឃើញទេណាស់ រាប់លុយសុទ្ធតែអញ្ចេក
សុទ្ធតែបែរអញ្ចេក ហើយដល់ពេលហើយទៅញ៉ុមក៏អត់ឃ្លានមើលរបស់គាត់ដែរ។

ក៖ ចាំ!!

ខ៖ នឹកឃើញអញ្ចេក
នឹកឃើញថាគេចង់ផ្ញើអោយកូនគាត់ប៉ុន្មានប៉ុន្មានទៅយើងអត់ដេញដើងសួរទេណាស់
កាលណាយើងដេញយើងយើងសួរថាយើងហ្នឹងសួររឿងលុយឥឡូវហើយអញ្ចឹងកុំអោយ
សោះអីចឹងដល់ពេលហើយទៅសុំមើលអីតិចតួចអីចឹងទៅបាន !!

ក៖ ចា!!

ខ៖ តែគ្រាន់តែថាយកអីមកមើលអីរាប់អីនៅហ្នឹងដៃអីអត់បានទេ!!ញ៉ុមកំរណាស់!!

ក៖ អត់មានអោយអីមីងសោះម៉ងហើយហោ?

ខ៖ អោយ អោយដែរអោយដូចថា២០ ៣០ហ្នឹងអោយមែន(ដុល្លារ)ញ៉ុមនិយាយថ្ងៃស្មើហ្នឹងហ៎!តែតែឃើញយើងទិញអីស៊ីផ្តេកផ្តាសស្តី អោយមុខគេខ្មាស់គេឥឡូវហើយ។

ក៖ ហ៊ឺ!!

ខ៖ ដល់ពេលយើងទិញ យើងចង់ទិញអីអញ្ចឹងហាំ ទីញអីក៏ដោយកុំអោយគាត់ឃើញ តែឃើញហ្នឹងស្តីអោយឥឡូវ ញ៉ុមទិញទិញ និយាយអោយនិយាយទៀតខ្មាស់គេឥឡូវហ្នឹង ហ៊ឺ!!ហ្នឹង!!

ក៖ សុទ្ធតែអញ្ចឹងទៀត??

ខ៖  ហ្នឹងអ៊ីចឹង ទិញរបស់របរអីអោយយើងលក់ដូរទៅ!!

ក៖ ហ៊ឺ!!

ខ៖ ហើយមួយហឹកហ្នឹងញ៉ុមអត់ចេះនិយាយដូចគេ ញ៉ុមចេះនិយាយតែការណាពិតទេមីអូន។

ក៖ ចាំ!!

ខ៖ និយាយតែការពិតទេ!!

ក៖  ហ៊ឺគំរិះមែនហេ?

ខ៖  ហ្នឹង!!ញ៉ុមទៅសាសនាមុនញ៉ុមទៅអត់រអ៊ើទេ ឥឡូវរអ៊ើហាំ!!

ក៖  ម៉េចអញ្ចឹងវិញ?

ខ៖  ដូចថាគាត់ហ្នឹងចង់អោយញ៉ុមលក់ទឹកលក់គោជល់លក់ខារ៉ាបារអីអញ្ចឹងទៅដើម្បីជីវភាព ដោយសារពេលគាត់ទៅវិញអត់មានអ្នកណាគេចិញ្ចឹមកូន។

ក៖ ហាំ ហើយដល់ពេលគាត់ទៅ គាត់ចង់ទៅទៅផ្តាច់ចោលអញ្ចឹងម៉ងហើយហេ?

ខ៖  ដូចថាទុកអោយតិចតួចអ៊ីចឹងដូចថាអោយយើងរកស៊ីអីអញ្ចឹងទៅណាស់មីអូន ដល់ពេលហើយទៅ

ហោញុំមចូលសាសនាយូរហើយដល់ពេលញុំមអ់តអោយញុំមទៅម៉េចអត់អោយអត់បានទេ
ដល់ពេលហើយទៅព្រឹកមិញហ្នឹងមកហើយទៅលឺសូរម៉ែញុំមនិយាយម៉េចទេ
ជាមួយប្អូនញុំមជជែកគ្នាថាឮសូរញុំមនិយាយថាញុំមទៅវិហារលឺសូរញុំមនិយាយអញ្ចឹង
តែញុំមប្រាប់គាត់ថាញុំមនៅណោះញុំមទៅវិហារ គាត់ដូចថាគាត់ស្មានតែញុំមទៅលេងហាំ
ញុំមប្រាប់គាត់ហើយថាញុំមទៅវិហារ
ដល់ពេលញុំមតេមកលឺសូរទូរសព្ទ័ញុំមនិយាយប្រាប់ម៉ែញុំមហាំ ថាញុំមទៅវិហារ
ដល់ពេលឮសូរថាញុំមទៅវិហារធាក់កង់ទៅផ្ទះរុយ ញុំមមកមានទាន់ណា
ម៉ែញុំមនិយាយញុំមចុះលើអាកង់៣មកដល់ ម៉ែញុំមប្រាប់ថាទៅវិហារ
ដល់ហើយញុំមថាអញ្ចេក ហុីញុំមធ្លាប់ចូលហើយ ធ្លាប់ចូលប៉ុន្មានឆ្នាំហើយ ៤ ៥ ៦ឆ្នាំហើយ។

កៈ អញ្ចឹងគាត់មកនៅគាត់អត់ដែលទៅចិនវិញណាមីងហោ?

ខៈ គាត់ទៅមកទៅមកអញ្ចឹង គាត់ទៅលេងអញ្ចឹង !!

កៈ ហ្អូ!!

ខៈ ដល់ពេលហើយទៅញុំមថាអញ្ចេក មីអូន
ហុីញុំមធ្លាប់ទៅហើយអត់អោយញុំមអត់អោយញុំមអ់តទៅម៉េច!!

កៈ កុំបោះបង់ចោលអ្នកមីង កុំអោយសោះ!! តែអធិស្ឋានអោយគាត់វិញទៅ!!

ខៈ ហើយញុំមដូចថា ដូចថាថ្ងៃណា គាត់កិនយើងខ្លាំងអញ្ចឹងណាស់
ញុំមដូចថាទៅខ្លះខានខ្លះអញ្ចឹងទៅណាស់ ថាអញ្ចេកប្រសិនបើគាត់ទៅណោះដាច់ហាំ
ខ្ញុំធូរទ្រូង ដូចថាអញ្ចេកញុំមបានទៅវិហារ!!

កៈ ហុី!!

ខៈ ញុំមបានទៅហើយញុំមនឹកឃើញថាអញ្ចេកទ្រាំ
ថាអញ្ចេកទ្រាំតែមួយឆ្នាំពីរឆ្នាំហិ!!ទៅវិញទៅណាស់ ញុំមទៅវិញអាហ្នឹងញុំមទៅ
គាត់ទៅវិញហើយ
អាហ្នឹងញុំមបានទៅវិហារជាប់!!ញុំមសុខចិត្តថាថ្ងៃអាទិត្យថ្ងៃអីអញ្ចឹងទៅញុំមទៅវិហារអញ្ចឹង
ទៅណាស់ថ្ងៃចន្ទ័ថ្ងៃអង្គារញុំមលក់ទឹកអញ្ចឹងទៅ
ដោយសារញុំមរកស៊ីចិញ្ចឹមកូនអញ្ចឹងទៅណាស់។

ក៖ ចាំ!!

ខ៖ គិតថា ថាអត់ពីប្តីទៅយើងខំប្រឹងប្រែង រកស៊ី!!

ក៖ ហើយចុះមីងមិនព្រមយកប្តីខ្មែរយើងហ្នឹងអីវ៉ាន់អញ្ចឹងទៅ
បាននៅជាមួយគ្នារហូតអ៊ីចឹងទៅ?

ខ៖  ចង់និយាយថាអញ្ចេកខ្ញុំយកប្តីចិនហ្នឹងខ្ញុំអត់ចង់យកទេ
តែដូចថាបងប្អូនកូនក្មួយអ្នកធ្វើការហើយអ្នកនៅភ្នំពេញបងប្អូនអីអញ្ចឹង
ដូចញ៉ុមនិយាយប្រាប់ហ្អែងហូរហែរអ៊ីចឹងណាស់ ញ៉ុមអត់ចង់យកទេ!!

ក៖  ហើយចុះតាំងពីក្មេងមកមិនព្រមយកអីអោយហើយទៅអត់ទេ?

ខ៖
អត់បានអញ្ចឹងញ៉ុមនិយាយថាអញ្ចេកគ្រាន់តែទ្រាំចាំគាត់ទៅបានអីទៅបានធូរទៅញ៉ុមបានទៅ
វិហារជាប់ហើយ!!

ក៖ ហ៊ីអ៊ីចឹង ហ្នឹង អត់សូវខ្វល់រឿងប្តីសីអីណាប៉ុន្មានទេមីងណោះ?

ខ៖  អញ្ចេក
ដូចថាអញ្ចេកដូចថាគាត់មានប្រពន្ធនៅណោះមានប្រពន្ធនៅស្រុកណោះហើយអញ្ចឹងគាត់ដា
ច់ប៉ាស់ស្ព័រ១០ឆ្នាំ ហើយគាត់បន្តទៀតក៏បន្តទៅហើយបើអត់បន្តក៏ញ៉ុមអត់ដឹងធ្វើម៉េចដែរ
ហើយញ៉ុមស្រលាញ់គាត់អ៊ិចឹងតែធ្វើម៉េច បើគាត់ទៅក៏ទៅទៅ ។

ក៖  យ៉ាប់ដែរហ្នឹងមីងដោយសារគាត់មានប្រពន្ធមានអីនៅណោះហ្ន៎!!

ខ៖ អញ្ចឹងបានថាមានប្រពន្ធកូននៅណោះហើយ ហើយអញ្ចឹងប្រពន្ធកូនគេ ប្រពន្ធកូនគេ
ប្រពន្ធកូនគេយើងដូចថាអោយគាត់ទៅអ៊ិចឹងទៅណាស់ !!
យើងអោយទៅស្រួលទៅវិញស្រួលកុំអោយគេថាហ៊ីមីនេះចង់ធ្វើឃោរឃៅ
ហួងហែងតែយើងហ្នឹងអ៊ីចឹងហាំ!!

ក៖ ចាំ!!

ខ៖ ក៏វាមិនកើតដែរ!!

កៈ ហ៊ឺៗ!!

ខៈ អញ្ចឹងហើយអញ្ចឹងយើងត្រូវតែចេះពិចារណាគិតកន្លែងហ្នឹងអោយដឹង!!

កៈ ដូចមើលទៅអត់សូវស្រួលប៉ុន្មានដែរហ្នឹងជីវិតរបស់អ្នកមីង!!

ខៈ អ់តសូវស្រួលទេញ៉ុមប្រាប់ទៅ។

កៈ ហើយបានប្ដីហើយក៏មិន!!

ខៈ ពេលខ្លះយើងអត់អី
ដូចថាយើងអត់ចេះរកស៊ីអីអញ្ចឹងណាស់ញ៉ឹងស្លឹកត្រចៀកយើងអញ្ចឹងហា!!

កៈ ធ្វើអញ្ចឹងទៀត?

ខៈ ញ៉ឹងលេងអីអញ្ចឹងទៅណាស់!!កៈ ហ្ហ៎!!ខៈ គាត់ថាអោយខំរាល់ថ្ងៃអោយខំ ហើយញ៉ុមហា៎
ជូនកាលញ៉ុមធ្វើការរោងចក្រអីអញ្ចឹងណាស់ ដល់ពេលហើយគាត់អូសដៃញ៉ុមថាណោះគេលក់
លក់
លក់ហើយមកនិយាយជាមួយញ៉ុមធ្វើការរោងចក្រញ៉ុមធ្វើការរោងចក្រញ៉ុមបង់លុយរដ្ឋមួយខែ
១០០ជាង(ដុល្លារ)មួយខែ១០០ជាង មួយខែ១០០ជាង!!

កៈ ហ៊ឺៗ!!

ខៈ រាល់ថ្ងៃហ្នឹងហា៎!មួយខែ១០០ជាង មួយខែ១០០ជាង!!

កៈ ហ៊ឺមីងចូលផ្លូវមួយហ្នឹងមិនសូវស្រួលប៉ុន្មានទេនេះ!!

ខៈ ចា៎ដល់ពេលហើយខំនិយាយអង្វរគាត់ថាអញ្ចេក
អោយគាត់ជួយបង់លុយរដ្ឋលុយអីខ្លះទៅណាស់!!

កៈ ហ៊ឺ!!

ខៈ ហ្នឹងរាល់ថ្ងៃហ្នឹងកំពុងតែគិតអញ្ចឹងណាស់មីអូនណាស់!!

កៈ ចា៎!!

ខ៖
មឹងនិយាយអីចឹងខុសឬក៏ត្រូវញ៉ុមនិយាយអីចឹងញ៉ុមខ្លាចតែញ៉ុមនិយាយខុសព្រោះអីញ៉ុមអត់សូវចេះអក្សរ ញ៉ុមនិយាយអត់សូវបាន!

ក៖ អត់អីទេមឹង!!

ខ៖ អត់សូវចេះពិចារណាអី អត់ចេះគិត!!

ក៖ ហ៊ុំអត់អីទេ មានអីខុស!!

ខ៖ ព្រោះអីថាញ៉ុមច្រើនតែភ្លេចមុខភ្លេចក្រោយ!!តែញ៉ុមបើនិយាយពីប្ដីប្រពន្ធញ៉ុម!!

ក៖ គាត់ស្រួលដែរ?

ខ៖ ស្រួលដែរ!!

ក៖ តែគ្រាន់តែលុយកាក់ក៏មិនសូវស្រួលអីប៉ុន្មានដែរ?

ខ៖ លុយកាក់គាត់កាន់
គាត់មិនមែនអោយយើងទៅទិញខ្លាំងៗៗៗស៊ីចាយហ្វៀយហៃទេណាស់!!

ក៖ ហ៊ុំៗ!!

ខ៖ មិនមែនទេ ហើយមិនមែនថាបើកលុយមកណោះប្រពន្ធយក១០០ទៅ!!

ក៖ តែគាត់និយាយខ្មែរអីច្បាស់ទាំងអស់?

ខ៖ និយាយខ្មែរ!!ស្ដាប់បានខ្មែរអីទាំងអស់!!

ក៖ និយាយបានទាំងអស់ស្ដាប់បានទាំងអស់ហេ?

ខ៖ និយាយខ្មែរខ្លះៗ!! មិនមែនបើកលុយមកថា ណោះប្រពន្ធយក៥០ យក២០០
យក៣០០អីទៅ អត់ទេ សូមជំរាបមីអូន សូមជំរាប
ទាល់តែថាអញ្ចេកឯងអើយញ៉ុមអត់លុយទេ សុំ៥ ១០រៀលអីអញ្ចឹងទៅ!!

ក៖ អីអោយតិចម្ល៉េះមឹង?

ខ៖  អោយ៥ ១០រៀលអញ្ចឹង ៥ ១០ រៀល ២០រៀល។

ក៖  តែរាល់ថ្ងៃអត់នៅផ្ទះជាមួយមីងទេហេ?

ខ៖  ខ្ញុំនិយាយស្មើរហ្នឹង ញ៉ុមអត់ចេះនិយាយនេះទេមែនមីអូនសួរតែម៉ែញ៉ុមមើលទៅ។ក៖ ហ៊ឺ!!ខ៖  មែនខ្ញុំនិយាយមែនសួរម៉ែខ្ញុំមើលទៅ !!

ក៖ ចាំ!!

ខ៖ ទាល់តែមានការអីធំដុំបានអោយយើង ថាអោយអីធំដុំថាអត់មានពិបាកនេះពិបាកអីទេ ដូចថាធ្វើអ្វីមួយធំដុំបានអោយយើង។

ក៖ ហ៊ឺ!!

ខ៖ សួរម៉ែញ៉ុមមើលទៅ នេះបានថាបានលុយហើយថាអោយណោះហ្អែងយក៥០ ១០០ទៅ ណោះប្រពន្ធយក១០០យក៥០ទៅ
អត់ទេហ្នឹង!អត់ទេតិចអ្នកណាគេអត់ដឹងថាអញ្ចេកថាប្តីចិនអោយលុយច្រើនៗណាស់!!
អត់មានទេខុសស្រឡះហើយ សួរតែបងស្រីញ៉ុមហ្នំ!!ព្ទ

ក៖  លុះត្រាណាតែចិនហ្នឹងគេមានកប់ !!

ខ៖ កប់ពពកម៉ង!!

ក៖  ធ្វើប្រធានរោចក្រ!

ខ៖  ប្រធានគេម៉ងបាននេះ!!

ក៖ ហ៊ឺ!!តែមិនមែនស្រួលប៉ុន្មានទេបងអើយ!!

ខ៖ អត់ស្រួលប៉ុន្មានទេ!!

ក៖  ដឹងហើយថាជនជាតិចិនគំរិះ!!!

ខ៖ ហ៊ីគំរិះណាស់!! តែខ្ញុំយកនេះខ្ញុំយក ខ្ញុំអត់ស្រលាញ់លុយទេ
ញ៉ុមអត់ចង់បានលុយពីគាត់ទេ
ញ៉ុមដឹងថាគាត់រិះហើយណាស់មីអូនណាស់ញ៉ុមនិយាយអ៊ីចឹងម៉ងទៅណាស់!!

ក៖ ហ៊ឺ!!!

ខ៖ ដូចថាគាត់គំរិះហើយយើងចង់បានទារលុយគាត់ពិបាកណាស់កុំ
បើគាត់យកមកបើកមកអោយអោយទៅមិនអោយហីទៅ!!ក៖ ហ៊ឺៗ!!ខ៖
តែតែកូនញ៉ុមឈឺថ្កាក់អីញ៉ុមបីកូនញ៉ុមទៅហើយ ងាប់ហើយ!!!!

ក៖ តែគាត់មកនៅផ្ទះណេះឬក៏គាត់មកនៅរោងចក្រ?

ខ៖ គាត់ដូចថាពេលគាត់ធ្វើយប់អញ្ចឹងពេលថ្ងៃគាត់មក មួយថ្ងៃពីរថ្ងៃបីថ្ងៃអ៊ីចឹងទៅណាស់
ហើយគាត់ទៅវិញ!!

ក៖ ចុះអត់មានផ្ទះអីនៅរោងចក្រអីណាហី?

ខ៖ អត់ទេ អត់មានទេ ផ្ទះរោងចក្រហី អត់មានផ្ទះទេ
ហើយអញ្ចឹងអ្នកខ្លះនិយាយថាអញ្ចេកហ៊ីហ្អែងបានប្តីចិនកោរគេអីយកទិញដីទិញអីទៅ
ទិញអីអញ្ចឹងទៅអោយកូនអោយអីនៅអ៊ីចឹងទៅ ញ៉ុមថាហ៊ីញ៉ុមអត់ចេះនិយាយកោរគេម៉េចទេ
ញ៉ុមអត់ចង់បានទេ!!

ក៖ អត់ទេដោយសារអញ្ចេក!!

ខ៖ ញ៉ុមអត់ចង់បានទេ!!

ក៖ របៀបអញ្ចេកមីងដូចថាដើម្បីកូន ដោយសារមីអូនដល់ពេលទៅ
ដល់ពេលអនាគតទៅក៏អត់សូវមានអីគេច្រើនដែរអញ្ចឹងអ្នកមីងគួរតែនិយាយជាមួយប្តីទៅ!!

ខ៖ អត់ទេ អត់ទេនិាយយហើយ និយាយម៉េចក៏អត់នេះដែរ!!

ក៖ អត់ព្រមអោយទេណោះ?

ខ៖ អត់ព្រមអោយដែរ គាត់ថា!!

ក៖  ដើម្បីកូននេះអានិតកូននេះ!!

ខ៖  ញ៉ុមនឹកឃើញថាកូនគេហ្នឹងហើយបើយើងចង់បានយកនិយាយមើលសភាពការសិន គាត់តឹងរឹងណាស់ គាត់តស្រួលជាមួយយើងនិយាយជាមួយយើងថា ហ្អែងហិយកប៉ុណ្ណេះៗយកទៅទិញអី ទិញដីទិញផ្ទះអីហ្នុ៎ ហ្នឹងចាំយើងអាចជាមួយគាត់ គាត់តឹងដូចខ្មែរចាប៉ុអិចឹងកុំ តឹងណាស់មិនងាយទេ!!

ក៖ ដូចរបៀបរៀបការជាមួយគាត់មានកូនតែមួយតើអ្នកមីងហេ?

ខ៖  មានកូនតែមួយទេ។

ក៖  មីអូនឈ្មោះអីគេវិញ?

ខ៖  ម៉ីម៉ី!!!សាវ ម៉ីម៉ី!!

ក៖  កូនខ្មែរកាត់ចិន! ចុះគាត់តអត់មានដូច!!

ខ៖  ហ៊ីពិបាកណាស់ អត់ស្រួលទេ ពិបាកណាស់មិនងាយទេ!!ក៖ ចាំ!!ខ៖ ប្អូនញ៉ុមប្អូនប្រុសក៏អញ្ចឹងដែរ!!

ក៖ ហ៊ីៗ!!

ខ៖ វេទនាណាស់បើយើងអត់លុយវាមើលងាយយើង ពិបាកណាស់វាមិនងាយទេនៅគ្រួសារជាមួយគ្នាអញ្ចឹង!!

ក៖  នៅជុំគ្នា!!មិនស្រួល!!ចាំ!!អញ្ចឹងមីង!!

ខ៖  អ៊ីចឹងបានថាម៉ែមួយកូនមួយគាត់ទៅបាត់ទៅយើងមិនបាច់យកប្តីយកអីទៀតទេ យើងនៅតែនៅថែរក្សារកូនចៅ!!

ក៖ ពេលមុនបើសិនជាយកជនជាតិខ្មែរយើងទៅនៅជាមួយគេទាល់តែចាស់!!

ខ៖ ដល់ពេលញ៉ូមតាំងចិត្តថាអត់យកម៉ង!!

ក៖  ហ្នុំចិត្តខ្លួនឯងបងចាន់ថាតាំងចិត្តអ៊ីចឹងដែរអត់?

ខ៖  តាំងដែរ!! តែដូចថាអញ្ចេកបើសិនជាញ៉ុមយកញ៉ុម
ញ៉ុមជ្រើសរើសយកថាអ្នកណាល្អដែរណាស់ មិនយកអ្នកស្រវឹកព្រឹកស្រវឹងល្ងាចអីទេ!!

ក៖  ហ៊ីពីបាកណាស់មនុស្សសម័យឥឡូវប្រុស!!ចុះឥឡូវមីអូនរៀននៅមីង៕

ខ៖ ចាំ??

ក៖ មីអូនរៀននៅ ចូលរៀននៅ?

ខ៖  នៅផង។

ក៖  ឥឡូវប៉ុន្មានឆ្នាំហើយ?

ខ៖  ៣ឆ្នាំ៥ខែហើយ!!

ក៖  ហ្ន៎ទឹមបាន៣ឆ្នាំជាងទេ!!

ខ៖  ៣ឆ្នាំ។

ក៖  មុខឡើងមូលតាល់ មុខកាត់ទៅឪមែនមីងហោ?

ខ៖  កាត់ទៅឪ។

ក៖ តែពេលមុនប្តីមីងធ្លាប់ទៅវិហារដែរតើមីងហី?

ខ៖
ធ្លាប់ទៅតើកាលមុន!!តែដល់ពេលឥឡូវដូចថាគាត់រៀងជិតទៅស្រុកទៅអីអញ្ចឹងណាស់!!គាត់
ស៊ីឈ្នួលគេតើ!!ហ្នឹង!

ក៖ អ៊ីចឹងមីងសំរាប់ចូលដល់មួយទៀតសំរាប់ប្រទេសយើងសង្គ្រាមប៉ុល ពតលន់
នល់អីវ៉ាន់អ៊ីចឹងទៅមីងណាស់។

ខ៖ ចាំ!

ក៖  មីងកើតមកទាន់ហើយតែគ្រាន់តែថាមីងនៅតូចមែនទេ?

ខ៖  ទាន់នៅទូចចាំ!!

ក៖  មីងចាំអីគេខ្លះពេលជំនាន់សង្គ្រាមហ្នឹងអីទេ?

ខ៖  ញ៉ុមចាំដូចថាពិបាកវេទនាអត់អីហូប។

ក៖ មើលជីវិតមីងពេលហ្នឹងម៉េចដែរ ជួបរឿងអីគេខ្លះ?

ខ៖  មើលកាលញ៉ុមនៅទូចៗហា ទៅចូលវង់
ទៅចូលវង់គេគុគេហាំ!!គ្រែគេអង្គុយហ្នឹងហាសម្លរញ៉ុមដាក់វង់ខ្ញុំទាន់ដូសញ៉ុមចំជន្លេន!!

ក៖ ចំ!!

ខ៖ អាត្រកួនខែប្រាំងវាវា ហ៊ី!!

ខ៖ អាត្រកួនធ្លាក់ភ្លៀងហាំ!!

ក៖ ចាំ!!

ខ៖ ហើយវាវា វាមិនជាប់ត្រកួនហើយគេលាងត្រកួនអត់ស្អាតហ្នំ !!

ក៖ ហ៊ី!!

ខ៖ ចំវង់ខ្ញុំចំជន្លេនហ្នំ!!

ក៖ ហើយម៉េចទៅអញ្ចឹង ?

ខ៖  ហើយស្លរហ្នឹងស្លរដាក់តែអំបិលស្លរអត់មានបង់ប្រហុកផងហ្នឹង បង់តែត្រីបង់តែអំបិល
ដាក់តែបន្លែហ្នឹងហើយដាក់តែម្ជូរហ្នឹង!!

ក៖ ហ៊ី!!

ខ៖ ហើយអ្នកណាទាន់ទាន់ទៅ ហូបទៅអ្នកណាទៅមិនទាន់វេទនាអញ្ចឹងទៅ
អាហ្នឹងនិយាយអោយអស់អញ្ចឹងទៅមិនមែននិយាយអីទេ!!

ក៖ ហើយដួសជន្លេនហ្នឹងហើយហូបទៅ?

ខ៖  ដូសអាជន្លេនហ្នឹងហើយហូបទៅអាហ្នឹងអីចឹង។

ក៖ ចាំ!!

ខ៖ ហើយពេលបានបាយសុទ្ធហូបម្តងៗ ហូបទៅអរណាស់!!

ក៖  ហ៊ី!!មីងប៉ុន្មានឆ្នាំពេលហ្នឹង?

ខ៖
ញ៉ុមនិយាយហាំញ៉ុមនិយាយប្រាប់គេថាអូយមីងឯងចំជន្លេនហើយញ៉ុមនិយាយប្រាប់ម៉ែញ៉ុម
ហ្នឹង ប្រាប់ថាហ៊ីពិបាកណាស់!

ក៖ តែគ្មានអីទេជន្លេន!!

ខ៖  តែអាហ្នឹងនេះតើ!!

ក៖ ដី!!

ខ៖  ដីវាស៊ីដីហ្នឹង។

ក៖ ចាំ!!

ខ៖ ហើយអាហ្នឹងក៏ថ្នាំដែរ។

ក៖  តែគ្រាន់តែយើងអាសត្វជន្លេនហ្នឹងវាមនុស្សវាខ្ពើម។

ខ៖  ធ្វើយឺតៗវាអោយយើងខ្ពើមហាំ!!

ក៖  ហ្នឹងហើយតែតាមពិតវាខ្ពើមយើងដែរទេហី?

ខ៖
ជួនកាលយើងអត់បាយហូបហ្នឹងក៏មានដែរ!!អត់មានបាយហូបក៏មានដែរដេកអត់បាយក៏មាន
ដែរ ជំនាន់ញ៉ុមនៅទូចៗ ឈឺវិលមុខ!!!!ចាំ!!

ក៖  អីចឹងអ្នកសំរាប់ពេលនៅក្នុងហ្នឹងអ្នកមីងធ្លាប់ឮមានគេយកមនុស្សទៅសម្លាប់ចោលអីអត់?

ខ៖  ញ៉ុមកាលហ្នឹងនៅទូចៗអត់សូវនេះដែរឮតែគេនិយាយដែរហ្នឹង។

ក៖  គេនិយាយថាម៉េចដែរមីង?

ខ៖  គេនិយាយថាគេយកទៅសម្លាប់ចោលសម្លាប់ច្រើនអីនៅកោះគរហ្នឹងហាំ!!

ក៖  ហ្នឹងហើយ !! នៅត្រើយម្ខាងហ្នឹងម៉ងហី?

ខ៖  ហ្នឹងហើយនៅត្រើយម្ខាងហ្នឹង !! សុទ្ធតែក្បាលខ្មោច សួរមីងស្រីក៏គាត់ដឹងដែរ!!

ក៖ ចាំ!!

ខ៖ កាលហ្នឹងក្បាលខ្មោចច្រើនណាស់មីងស្រីណោះ កាលខ្មោចកោះគរហាំ?

(មីងស្រីអ្នកជិតខាង)៖ ក្បាលខ្មោចច្រើនតើ!!

ខ៖  ក្បាលខ្មោចច្រើន!!

(មីងស្រីអ្នកជិតខាង)៖ ក្បាលខ្មោចច្រើន
ក្បាលខ្មោចឥឡូវគេយកមកដាក់វត្តឈូងលៀបអីអស់ហើយ!!

ក៖ ចាំ!!

(មីងស្រីអ្នកជិតខាង)៖ ក្បាលខ្មោចហ្នឹង!!

ក៖  ច្រើនណាស់មីងណោះ?

(មីងស្រីអ្នកជិតខាង)៖ ចាំ!!

ក៖  ជំនាន់ប៉ុល ពតមីងនៅណាវិញ?

ខ៖  ជំនាន់ប៉ុល ពតនៅព្រៃកខ្សេវណោះម៉ែណោះ?

(ម្ដាយរបស់អ្នកមីង)៖ នៅព្រៃកខ្សេវ។

ក៖  នៅព្រៃកខ្សេវ ណោះហោ?

ខ៖ ព្រៃកខ្សែរហើយបានញ៉ុមមកនៅណោះ នៅសំប៉ាន់ ហើយញ៉ុមបានមកនៅព្រៃកខ្សែរ នៅព្រៃកខ្សែរហើយបានញ៉ុមមកនៅនេះ!!

ក៖ អញ្ចឹងចេះតែជំលៀសទៅក្រោមទៅក្រោមអញ្ចឹងទៅមីងណោះ?

ខ៖ ចាំ!!
ហើយធ្វើបន្លែធ្វើអីអញ្ចឹងទៅទូលអាចមន៍គោទូលអីអញ្ចឹងទៅ!!ចុះអាចមន៍គោមួយពំនូកធំប៉ាញ៉ូមហាំ ២ ៣ពំនូកទូលទៅហើយ!!ទូល ទូលទៅរាល់ថ្ងៃ ទូលធ្ងន់ៗណាស់!!

ក៖ ដូចគេអត់ធ្វើទារុណកម្មអីដែរមីងហោ?

ខ៖ អត់ទេញ៉ុមនិយាយកាលជំនាន់ចំបក់ប៉ាខ្ញុំនេះហិ។

ក៖ ហ្វ៊ូ!!

ខ៖ កាលជំនាន់ប៉ាខ្ញុំធ្វើបន្លែហ្នឹង!!

ក៖ ប៉ុន្តែនៅក្នុងប៉ុល ពតហ្នឹងមានអ្នកណាគេ?

ខ៖ កាលនៅក្នុងប៉ុល ពត ញ៉ុមបែកហើយគេទៅរែកដីញ៉ុមទៅតាមគេ ទៅតាមគេទៅហើយអត់មានបាយស៊ីទេ!!

ក៖ ហ៊ឺ!!

ខ៖ ហើយមិនដែលបានស៊ីឆ្អាញ់ទេ!!

ក៖ ហើយអ៊ីចឹងពេលប៉ុល
ពតហ្នឹងអ្នកមីងនៅជាមួយម្តាយឬក៏គេអោយនៅក្នុងកងកុមារអ៊ីចឹង?

ខ៖ កងកុមារ នៅកងកុមារនៅកងជាមួយគេ!

ក៖ ចាំ!! ប្រហែលប៉ុន្មានឆ្នាំមីងពេលនៅ?

ខ៖ ហោខ្ញុំនៅប្រហែលប៉ុន្មានឆ្នាំទេ តាំងពី!!

ក៖ មីងទឹមតែ៤ ៥ឆ្នាំហ្នឹងអ៊ីចឹងហ្វ៊ូ!!!

ខ៖  ហ្នឹងទឹមតែ៤ ៥ឆ្នាំហ្នឹង!!

ក៖  ទូចមួយហ្នឹង។

ខ៖  ទូចមួយនៅទូចហ្នឹង!!

ក៖ ចាំ!!

ខ៖ នៅខ្ទង់អាយុប្រហែលជា៨ឆ្នាំហើក៏ប៉ុន្មានឆ្នាំទេ ញ៉ុមអត់ចាំទេ!!

ក៖ ចាំ!!

ខ៖ ហើយញ៉ុមអត់ចាំទេ!!

ក៖ ហើយមីងពេលបែកប៉ុល ពត ម៉េចដែរ
ផ្លាស់ប្តូរអីអត់ឬក៏គ្រាន់តែអត់សូវដឹងអីទៀតម៉េចដែរ?

ខ៖  វារៀងសប្បាយចិត្តពេលបែកពីអាពតមកដូចថាវារាង ដូចថាវារាងធូរអីចឹងទៅណាស់ !!

ក៖ ហ៊ឺៗ!!

ខ៖ រាងធូរមិនមែនថាធូរនេះទេវារាងធូរ
ដូចថាអាខ្លះទៅលឺសូវគេនិយាយថាត្រូវសម្លាប់ចោលសម្លាប់អីកាលនៅជំនាន់ពេលអាពតហ្នឹងហាំ!!

ក៖ ចាំ!!

ខ៖  ហ្នឹងរៀងធូរជាង ហើយញ៉ុមលង់ទឹកតើ
ចំបក់អាពតម៉ែញ៉ុមទៅធ្វើការនៅក្នុងចំបក់អាពតញ៉ុមលង់ទឹកតើ លង់ទឹក!!

ក៖  ម៉េចវិញមីង?

ខ៖  លង់ទឹកនៅសក់រុយៗទៅមានគេជួយញ៉ុមអូសមកទៅ!!

ក៖ ហ៊ឺៗ!!

ខ៖ ហើយធ្វើអោយញ៉ុមវង្វេងខួរក្បាលអីអញ្ចឹងទៅណាស់ ហើយទៅជាអត់ចេះអក្សរទៅជាអត់ចេះអីអញ្ចឹងទៅ!!

ក៖ មកពីអត់រៀនហ្នឹង!!

ខ៖ ហ្នឹង!!

ក៖ ចាំ!!

ខ៖ រៀនៗវារៀនអត់ចេះ វារៀនភ្លេចមុខភ្លេចក្រោយ!!ហ្នឹង!!

ក៖ ចាំ!! មីងពេលវេលាណាដែលមីងពិបាកជាងគេនៅក្នុងជីវិតទៅ?ពេលណាពិបាក?

ខ៖ ពេលវេលាពិបាកជាងគេដូចថាយើងដាំបន្លែធ្វើចំការធ្វើអីអញ្ចឹងទៅ ហើយណាមួយយកលុយរដ្ឋយកលុយអីវេទនាអ៊ីចឹងទៅ!!ក៖ ហ៊ឺ!!ខ៖ ហូបអត់គ្រប់គ្រាន់អ៊ីចឹងទៅ!!

ក៖ ចាំ!!

ខ៖ ហើយកាលបើយើងយកលុយរដ្ឋយើងហូបឆ្ងាញ់យើងអត់មានអីបង់អោយគេ ដល់កុំយើងកុំហូបឆ្ងាញ់!!

ក៖ ចាំ!!

ខ៖ ហូបតែត្រីអីអ៊ីចឹងទៅ ស្លម្ជូរ ស្លប្រហើរអីអញ្ចឹងទៅ!!

ក៖ ហ៊ឺៗ!!

ខ៖ ហើយអត់ដែលមានបានហូបអីឆ្ងាញ់អញ្ចឹងទៅ អត់មានទេ តែបើយើងហូបឆ្ងាញ់យើងជំពាក់គេតែឥឡូវ ហ្នឹងញ៉ុមនិយាយអោយអស់ក្នុងជីវិតហ្នឹង និយាយអោយអស់!!

ក៖ ចាំ ឥឡូវមីង ក្តីសង្ឃឹមដែលមីងស្រម៉ៃទៅថ្ងៃខាងក្រោយ សង្ឃឹមទៅលើអីគេដែរមីងក្នុងជីវិត?

ខ៖ ញ៉ុមសង្ឃឹមដូចថាញ៉ុមចូលសាសនាអីអញ្ចឹងទៅ
សង្ឃឹមថាព្រះនឹងជួយអោយដូចថាយើងលក់ទឹក លក់អីដាច់អិចឹងទៅ!!

ក៖ ចាំ!!

ខ៖ ឥឡូវញ៉ុមអត់ចូលរោងចក្ររោងអីទេ រកស៊ីលក់ទឹកសុទ្ធទឹកអីអញ្ចឹងទៅណាស់!!

ក៖ ចាំ!!

ខ៖ ហ្នឹងព្រះជួយខ្ញុំវិញទៅ!!

ក៖ ហ៊ីអត់អីទេមីងតិចទៀត!!

ខ៖ ញ៉ុមសង្ឃឹមថាព្រះជួយដូចថាយើងលក់ទឹកលក់អីដាច់អញ្ចឹងទៅ!!

ក៖ នេះៗអ្នកនាំអោយជួយហ៎ តិចទៀតនឹង ដូចថារបៀបអញ្ចេក
គេបង្រៀនយើងដូចថាគេមិនចង់អោយអីយើងទេមីងណេះ!!

ខ៖ ចាំ!!

ក៖ តែបើបង្រៀនយើងចេះខ្លួនឯងហាំ!!

ខ៖ ចេះខ្លួនឯង!!

ក៖ យើងមានរហូត!! តែបើសិនជាគេអោយអីយើងថ្ងៃមួយវានឹងចប់ហើយ!!

ខ៖ ចាំ!!

ក៖ អារឿងយើងអញ្ចេកអាណាគេអង្គុយតែផ្តល់អីអោយយើងរហូតមែនទេមីង?

ខ៖ ចាំ!!

ក៖ តែបើសិនយើងមានជំនាញអីមួយរៀនដោយសារខ្លួនឯងហាំ!

ខ៖ ចាំ!!

កៈ ហើយយើងចេះរហូតហាំ!!
យើងអាចរកលុយបានរហូតពេញម៉ាជីវិតរបស់យើងអត់ចាំបាច់ទៅពឹងអ្នកណាគេ!!

ខៈ ចាំ!!

កៈ ទោះអត់អ្នកហ្នឹងអត់មកជួយក៏យើងអាចជួយយើងយើងបាន!!

ខៈ ហ្នឹងអាចជួយខ្លួនឯងបាន!!

កៈ ចាំហ្នឹងហើយ!!

ខៈ អញ្ចឹងបានថាញ៉ុមរាល់ថ្ងៃសង្ឃឹមដូចថាញ៉ុមអធិស្ឋានទៅព្រះអង្គហាំ
ព្រះអង្គជួយញ៉ុមលក់ទឹកដាច់អញ្ចឹងណាស់ ញ៉ុមនឹកឃើញអញ្ចឹងណាស់
ព្រះអង្គដូចថាញ៉ុមអធិស្ឋានទៅណែព្រះអង្គអើយជួយញ៉ុមអោយរកស៊ីមានបានអោយញ៉ុមល
ក់ទឹកអោយដាច់អញ្ចឹងទៅណាស់!!

កៈ ចាំ!!

ខៈ អោយញ៉ុមលក់ទឹកដាច់អោយបានរាល់ថ្ងៃអញ្ចឹងទៅ!!កុំអោយញ៉ុមអត់ លក់អោយដាច់ទៅ
អោយញ៉ុមលក់អោយដាច់ទៅអោយញ៉ុមរកចិញ្ចឹមកូនញ៉ុម!!

កៈ ចា!!

ខៈ ចិញ្ចឹមម៉ែឪកូនអីអញ្ចឹងទៅណាស់!!

កៈ អ្នកមីងថ្ងៃក្រោយទៅមានគំរោងអីសំរាប់មីអូន ដូចអោយគាត់ទៅរៀនចប់ចុងចប់ដើមហី?

ខៈ ញ៉ុមអោយរៀន អោយវារៀនអោយចេះដឹងដូចគេអញ្ចឹងកុំអោយល្ងង់ដូចខ្ញុំ!!

កៈ ចាំ!!

ខៈ ខ្ញុំល្ងង់អត់ចេះទេ។

កៈ មីងពេលគាត់គ្រប់អាយុធំពេលចូលរៀនស្រួតអោយចូលរៀនតិចទៅ !!

ខៈ ចាំ!!

ក៖ ដើម្បីអោយគាត់នេះ ហើយឈប់អីវ៉ាន់កុំអោយគាត់ឈប់ហាំ!!

ខ៖ ចាំ!!

ក៖ ដើម្បីអោយអនាគតទៅភ្លឺស្វាងទាំងមីងភ្លឺស្វាងទាំងគាត់!!

ខ៖ តែញ៉ុមនឹកឃើញថាអញ្ចេកញ៉ុមអត់មានលុយអីរៀនអង់គ្លេសអង់អីទេ!!

ក៖ អើយវិហារខ្វះអីមីងអើយ!!

ខ៖ អើយចង់និយាយថាអោយគ្នារៀនអើយរៀនអក្សរ!!

ក៖ ចិន!!

ខ៖ អោយបានចេះ កុំអោយដូចញ៉ុម ហើយរៀនចិនរៀនអីអញ្ចឹងទៅណាស់!!!

ក៖ ហ្នឹងហើយ លោរថ្ងៃណាមួយទៅលេងឪនៅចិន!!

ខ៖ ក្រែងលោរឪវា មិនអោយរៀនជ្រៅជ្រះអីណា ចិនអីជ្រៅជ្រះអីទេ ដូចថាអោយរៀនល្មមនិយាយជាមួយឪវា ឪវាគេមកអញ្ចឹងទៅណាស់!!

ក៖ ហ៊ឺៗ!

ខ៖ ដូចថាឪវាអោយទៅលេងទៅអីអញ្ចឹងទៅ!!

ក៖ ចាំ!!

ខ៖ អាហ្នឹងនេះតែប៉ុណ្ណឹងទេ!!

ក៖ ប្ដីមីងនៅខេត្តណានៅចិនឬក៏ប៉េកាំង? មីងគាត់នៅខេត្តណាវិញនៅចិនហាំដឹងទេ?

ខ៖ អី ខ្វាងទុងហី?

ក៖ ខ្វាងទុងហោ?

ខ៖ ខ្វាងទុង!!

កៈ ញ៉ុមចង់ទៅលេងចិននេះហិ ចាំមើលប្រហែលខែក្រោយទៅលេងចិនហើយ ចង់ទៅស្គាល់ប្រទេសចិនវាម៉េចដែរ!!

ខៈ ចាំ!!ខេត្តខ្វាងទុង!!

កៈ នៅចិនធំណាស់!!

ខៈ ចាំ!! អត់ទេបើហ្អែងចេះចិនអញ្ចឹងហាំខ្ញុំរកបានអញ្ចឹងហាំ ហ្នឹងខ្ញុំឧទាហរណ៍ទេណាស់ ក្រែងលោរញ៉ុមលក់ទឹកលក់អីរកបានទៅអញ្ចឹងទៅលក់ទឹកលក់អីដាច់អញ្ចឹងទៅមានលុយមានកាក់អីអញ្ចឹងទៅហ្អែងចិនចិនចេះអីអញ្ចឹងទៅ!!

កៈ ញ៉ុមអត់ចេះចិនហ្នឹងទេចេះតែអង់គ្លេស!!

ខៈ នាំញ៉ុមទៅលេងអញ្ចឹងទៅ!!

កៈ ញ៉ុមទៅតាមទេសចរណ៍គេហ្នឹងហាំ មីងហាំ!!

ខៈ អញ្ចឹងហោ?

កៈ អោយគេបកប្រែអោយដែរហ្នឹង!!

ខៈ ហ្ហ៎!!

កៈ បើអង់គ្លេសបានគ្រាន់!!

ខៈ ចាំ!!

កៈ ចិនញ៉ុមអត់ចេះទេ ដោយសារជើងវាច្រើនពេក!!

ខៈ ជើងវាច្រើន!!

កៈ ញ៉ុមអត់ចេះទេ!!!ចាំ!!អ៊ិចឹងអ្នកមីងសំរាប់អ្នកមីងចូលចិត្តពិសារម្ហូបអីគេដែរជាងគេ?

ខៈ ញ៉ុមហោ?

កៈ ចូលចិត្តហូបអីគេជាងគេ?

ខ៖  ហូបម៉េច?

ក៖  ដូចរបៀបម្ហូបហាំ!!ចំនង់ចំនូលចិត្តរបស់អ្នកមីង!!

ខ៖  ញុំមហេសម្លរម្ជូរ សម្លរប្រហើរអញ្ចឹងដូចថា ដូចតែយើងអញ្ចឹងណាស់។ក៖ ចាំ!!ខ៖ អង្គុយតែហូបឆ្ងាញ់រាល់ថ្ងៃអត់មានលុយ ហ្នឹងហើយសម្លរម្ជូរ សម្លរប្រហើរអីអញ្ចឹងទៅ។ក៖ ចាំ!!ខ៖ ហើយថ្ងៃណាយើងចង់ឆ្ងាញ់អីចឹងទៅយើងរកបានយើងហូបអញ្ចឹងទៅ ថ្ងៃណាអត់លុយអត់អញ្ចឹងទៅ ដូចតែគ្នាហ្នឹង ដូចមីងអញ្ចឹងថ្ងៃណាមានលុយអញ្ចឹងទៅទិញឆ្ងាញ់អញ្ចឹងថ្ងៃណាអត់លុយទៅនេះទៅ!!

ក៖  តាមហ្នឹងអញ្ចឹងទៅណោះ?

ខ៖  ចាំ!!ហើយតែហូបឆ្ងាញ់ឥឡូវបឹមអត់លុយបង់លុយរដ្ឋតែឥឡូវ។

ក៖  អីចឹងមីងរបៀបថាប្តីមីងហាំ គាត់ហូបអីគេវិញទៅ?ដូចថារបៀបម្ហូបចិន?

ខ៖  គាត់ហូបម្ហូបចិន ញុំមហូបអត់កើត!!

ក៖  គាត់ធ្វើខ្លួនគាត់អញ្ចឹងទៅ?

ខ៖ ចាំ!!

ក៖  ម្ហូបចិនហ្នឹងម្ហូបគេអីគេខ្លះទៅមីង?

ខ៖  សាច់ជ្រូកអីអញ្ចឹងទៅ មាន់អីអញ្ចឹងទៅ ក្រុមហ៊ុនគេធ្វើអោយហូបហាំ!!

ក៖ ហ្ហំ!!សុទ្ធតែមាន!!

ខ៖ ក្រុមហ៊ុនគេធ្វើអោយយើងហូប!!

ក៖ ចាំ!!

ខ៖ ស្ទោរស្តេ្ត ស្ទោរស្តេ្តហើយញុំមហូបចង់ដាច់ខ្យល់ហើយ !!

ក៖  និយាយថាស្ទោររហូតហ្នឹង?

ខ៖  ស្ងោរស្ពៃ ស្ងោរស្ពៃ ស្ងោរស្ពៃ ថ្ងៃណាក៏ស្ងោរស្ពៃ ស្ងោរស្ពៃសាច់ជ្រូក ស្ងោរស្ពៃសាច់ជ្រូក ស្ងោរស្ពៃសាច់ជ្រូក ស្ងោរសាច់ជ្រូកសុទ្ធ ស្ងោរសាច់ជ្រូកសុទ្ធ ស្ងោរសាច់ជ្រូកសុទ្ធ ហូស!!
តែអត់ហ៊ាននិយាយនៅមុខគាត់ទេ សុខចិត្តទុកនៅក្នុងចិត្តទៅណាស់!!

ក៖ ហ៊ឺ!!

ខ៖  ហ៊ឺទុកក្នុងចិត្ត ទុកក្នុងចិត្តទៅ ដូចថាគាត់ធ្វើអោយយើងហូបឆ្ងាញ់ទៅណាស់!!

ក៖ ចាំ!!

ខ៖ ហើយអ៊ីចឹងបានញ៉ុមនិយាយប្រាប់អ្នកនៅធ្វើការជាមួយញ៉ុម ញ៉ុមថាអញ្ចេក
ញ៉ុមកាលអត់ទាន់បានគាត់ហាំ អើរបានគាត់ក៏ធូរដែរ គាត់ទិញសាច់ជ្រូកអោយ
កាលអត់ទាន់បានគាត់ហាំ ញ៉ុមអត់ដែលបានហូបឆ្ងាញ់ទេ
ហ្នឹងញ៉ុមនិយាយអោយអស់ទៅណាស់!!

ក៖ ហ៊ឺៗ!!

ខ៖  ហ្នឹងញ៉ុមបានហូបឆ្ងាញ់បានតែម្តងម្កាលទេ!!ញ៉ុមនៅជាមួយម៉ែញ៉ុមញ៉ុមអត់ណាស់!!
ញ៉ុមហូបឆ្ងាញ់បានតែម្តងម្កាលទេ
ដល់ពេលញ៉ុមបាមគាត់គាត់ទិញសាច់ជ្រូកអោយហូបអញ្ចឹង
ញ៉ុមថាអើយឥឡូវអញបានហូបឆ្ងាញ់បន្តិចហើយព្រោះអីទៅ
ទៅគាត់ម្តងម្កាលគាត់ទិញសាច់ជ្រូកទិញសាច់អីអោយហូប តែសាច់គោអត់ដែលទេណាស់ !!

ក៖ ហ៊ឺៗ!!

ខ៖  តែសាច់ជ្រូក សាច់ជ្រូកទេ!! គាត់ថាអញ្ចឹងហើយមីបងឯងហ្នំ
កាលអត់ទាន់ពេលបានកូនបានគាត់ ហូបសម្លរម្ជូរ សម្លរប្រហើរ ឥឡូវបានគាត់
គាត់ទិញសាច់ជ្រូកអោយហូបគ្រាន់បើតិចហើយបងឯង!!គ្រាន់ហើយគ្រាន់បន្តិចហើយហ្នឹងអ៊ីចឹងហាំ!!

ក៖ ចាំ!!

ខ៖  ហ្នឹងហើយតែទៅកន្លែងគាត់ គាត់ទិញអោយហូបហើយ!!

ក៖ ចាំ!!

ខ៖ ហ្នឹងគាត់ឃើញយើងអត់ពីមុនទៅណាស់!!ទៅពេលមុនគាត់ថាមក២០០៩ឥឡូវ!!

ក៖ ២០១៩!!

ខ៖ ១០ឆ្នាំ ១០ឆ្នាំគាត់ដាច់ប៉ាស់ស្ព័រគាត់ទៅវិញគាត់និយាយហា!!ក៖ ចាំ!!ខ៖
ហើយគាត់ថាគាត់បន្តទៀតគាត់បន្ត គាត់អត់បន្តអត់ដឹងធ្វើម៉េច
តែបើគាត់មានលុយទៀតគាត់បន្តហើយអត់ដឹងធ្វើម៉េចបើអត់លុយគាត់អត់បន្ត ហើយគាត់
គាត់ថាអញ្ចេកពេលដូចថាគាត់ពិបាកពេកគាត់និយាយថា ចាំមើលពេលគាត់ទៅឆាយណា
គាត់អត់និយាយប្រាប់ញ៉ុមទេ ទៅបាត់ឈឹងសូន្យ!!!!

ក៖ អញ្ចឹងទៀត?

ខ ៖ហ្នឹងៗៗគាត់និយាយអ៊ីចឹងហាំ!!

ក៖ សុទ្ធតែអញ្ចឹតងទៀត?

ខ៖ គាត់និយាយអញ្ចឹងគាត់ថាហាំ គាត់និយាយ គាត់និយាយលេងជាមួយញ៉ុមអញ្ចឹងណាស់!!

ក៖ ហ៊ឺៗ!!

ខ៖ តែមិនដឹងជាគាត់និយាយលេងឬក៏អត់ទេ តែគាត់និយាយអ៊ីចឹង
ថាអញ្ចេកតែទៅឆាយណាគេទៅហើយ គាត់អត់និយាយអត់និយាយទេ
តែមិនដឹងជាគាត់និយាយលេងឬក៏និយាយមែនទេ!!! តែញ៉ុមគិតក្នុងចិត្តដែរហាំ
ញ៉ុមគិតក្នុងចិត្តថាអញ្ចេក
ថាបើឯងទៅប្រាប់ក៏ប្រាប់ទៅមិនប្រាប់ក៏ហើទៅក៏ញ៉ុមមិនដឹងធ្វើម៉េចដែរ!!
ញ៉ុមនិយាយអញ្ចឹងណាស់!!

ក៖ ហ៊ឺៗ!!

ខ៖ តែញ៉ុមអត់សំខាន់រឿងលុយទេ
សំខាន់រឿងថាអោយថាលៃម៉េចអោយតែស្រលាញ់ប្រពន្ធកូន!!

កៈ
តែលៃម៉េចកុំអោយតែយកមួយនេះទៅបានបាត់ហើយនេះហ៊ិ!!ភ្នែកទឹងកូនគេ!!អញ្ចឹងអ្នកមីងមួយនេះគឺជាសំនួរមួយចុងក្រោយ!

ខៈ ចាំ!!

កៈ
តើអ្នកមីងមានពាក្យពេចន៍អីចង់ផ្ដែផ្ដាំទៅកាន់កូនចៅមីងជំនាន់ក្រោយអោយពួកគាត់ដើរលើផ្លូវម៉េចដែរហើយម៉េចអញ្ចឹងណាស់?

ខៈ ហើយញ៉ុមផ្ដាំប្រាប់កូនចៅញ៉ុម ក្មួយញ៉ុម ដូចកូនបងច្រើបញ៉ុម
ដូចអាមួយដេកនេះអីវ៉ាន់អញ្ចឹងហ៊ិ មីមី អាភារៈអីអញ្ចឹតងទៅ
ញ៉ុមប្រាប់ថាហើយកូនញ៉ុមញ៉ុមប្រាប់ថាអញ្ចេកខំរកខំដូចថាដើរតាមផ្លូវល្អកុំដើរតាមផ្លូវគ្រឿងញៀនហាំ!! ហើយកូនស្រីហ្នឹងក៏ដោយ ដើរតាមផ្លូវល្អកុំដើរតាមផ្លូវអាក្រក់ហាំ!!
តែដើរតាមផ្លូវអាក្រក់ញ៉ូមអស់សង្ឃឹមហើយ ញ៉ុមប្រាប់កូនញ៉ុមថាអញ្ចឹងណាស់!!

កៈ ចាំ!!

ខៈ ព្រោះអីញ៉ុមស្រលាញ់កូនញ៉ុមមានកូនតែមួយទេ ហើយក្មួយៗញ៉ុមអញ្ចឹងដែរ
ដើរតាមតែផ្លូវល្អ កុំដើរតាមគ្រឿងញៀនណាស់ ដើរតាមគ្រឿងញៀនអត់ល្អទេ!!

កៈ ហ៊ឺៗ!!

ខៈ សុទ្ធតែសម្លាប់សុទ្ធតែកាប់ចាក់ !!

កៈ ចាំ!!

ខៈ សុទ្ធតែនាំជក់ម៉ាសុទ្ធតែនាំខូចខិល!!

កៈ ហ្នឹងហើយ!!

ខៈ ទាំងស្រីទាំងប្រុស !! ញ៉ុមនិយាយប្រាប់កូនញ៉ុមអញ្ចឹងណាស់ កូនញ៉ុមស្រី!!

កៈ ចាំ!!

ខ៖  ញ៉ុមនិយាយអញ្ចឹង ញ៉ុមរាល់ថ្ងៃញ៉ុមនិយាយប្រាប់កូនញ៉ុមថាអញ្ចឹងណាស់!!

ក៖ ចា៎!!

ខ៖ ញ៉ុមថាកូនឯងដើរតាមផ្លូវល្អកុំដើរតាមផ្លូវគ្រឿងញៀន ហើយកុំដើរតាមផ្លូវអំពើរអាក្រក់!!

ក៖ ហ៊ឺៗ!!

ខ៖  ហើយមិនមែនតែកូនញ៉ុមទេ ញ៉ុមនិយាយប្រាប់ដល់កូនគេទៀត កូនអ្នកជិតខាង កូនអ្នកជិតខាង!!

ក៖  ចា៎និយាយទៅតែដើរខុសមួយជើងហ្នឹងចប់ហើយអ្នកមីងណាស់!!!

ខ៖  ចា៎!ចប់ម៉ង ហើយបើកូនញ៉ុមដើរតាមផ្លូវអាក្រក់ហា៎ញ៉ុមអស់សង្ឃឹមនៅក្នុងជីវិតហ្នឹងម៉ង អស់សង្ឃឹមក្នុងជីវិត ញ៉ុមអត់ចេះអក្សរទេតែញ៉ុមចេះគិតដែរ ញ៉ុមអត់ចេះអក្សរទេ តែញ៉ុមអោយកូនញ៉ុមហ្នឹងដើរតាមផ្លូវល្អអោយខំរៀនគ្រាន់តែផ្តាំកូនតែប៉ុណ្ណឹងទេណាស់!!

ក៖ ហ៊ឺៗ!!ចា៎!!

ខ៖ អោយកូនខំរៀនហើយអោយកូនចូលសាសនាដូចញ៉ុមអញ្ចឹង!!

ក៖ ចា៎!!

ខ៖  ចូលសាសនាល្អ!!

ក៖  ធំឡើងធ្វើអ្នកផ្សាយសាសនា!!

ខ៖  ហ្នឹង!!

ក៖ រៀនចេះដឹងអីវ៉ាន់អញ្ចឹងមីងណោះ?

ខ៖  ចា៎រៀនចេះដឹង !!

ក៖ ចា៎!!

ខ៖  កុំអោយដើរតាមផ្លូវអាពួកអត់ល្អ វានាំយើងទៅអត់ល្អ ជើងក្រោមជើងក្រោម!!

កៈ  ចាំ អូខេ
អញ្ចឹងអរគុណច្រើនអ្នកមីងសំរាប់ការសំភាសន៍ហើយអ្វីទាំងអស់កូនចៅអ្នកមីងគាត់នឹងបាន
ស្តាប់ហាំ!!

ខៈ  ហើយ ហើយ ឃើញដេញស្រុកឥឡូវឃើញអត់ល្អ ដូចថាសង្គមវារៀងដូចថានិយាយទៅ!!

កៈ  ចាំហ្នឹងហើយ!!

ខៈ  តែញ៉ុមនិយាយមិនដឹងខុសមិនដឹងត្រូវទេ!!

កៈ  ត្រូវហើយមីង ដោយសារឥឡូវវាអញ្ចឹងមែនណាស់!!

ខៈ  ឥឡូវអត់ល្អ ញ៉ុមមើលឥឡូវអាខ្លះវ៉ៃគ្នា
កាប់គ្នាហូរឈាមសុទ្ធតែអាករច្រកដាក់ចូលក្នុងធុងក្នុងអីហ្នឹង!

កៈ ហ៊ឺ!!

ខៈ  ឃើញទេអាខ្លះសុទ្ធតែសម្លាប់ដាក់ច្រកចូលក្នុងបាវ!!

កៈ  ហ្នឹងហើយ!!

ខៈ  អាខ្លះគ្រាន់តែមាស២ហ៊ុនហ្នឹង
រំលោភគេហើយសម្លាប់ច្រកបាវនៅក្នុងស្រុកព្រៃវែងហ្នឹង!!!នៅណាអីវ៉ាន់
នៅតាកែវអីណាណោះហ្នឹង ហ្នឹងញ៉ុមចេះតែលឺសូរគេនិយាយអីអញ្ចឹងទៅ!!

កៈ  ហ្នឹងហើយមែនមីង!!

ខៈ  ហ្នឹងគេផ្សាយវិតយោ គេផ្សាយពត៌មានអីញ៉ុមស្តាប់រាល់ៗព្រឹកហ្នឹង !!

កៈ ចាំ!!

ខៈ
ហ្នឹងហើយអញ្ចឹងបានញ៉ុមអោយបងប្អូនកូនក្មួយអីដើរតាមផ្លូវល្អហើយញ៉ុមហាំឧស្សាហ៍និយា
យប្រាប់កូនក្មួយ កូនក្មួយគេខឹងយើង។

កៈ ហ្នឹងហើយតែថ្ងៃក្រោយទៅដឹងហើយ ដើរខុសមួយផ្លូវអីហ្នឹងសុទ្ធតែដឹងខ្លួនហើយ។

ខៈ ចាំ!! ដូចយ៉ាងក្មួយៗញ៉ុមអីវ៉ាន់ហ្នឹងវាគ្រប់អាយុ១៧ ១៨ហា!! យើងអញ្ចឹងណាស់
ជួយកាលគេស្ដាប់ទៅ ជូនកាលគេខឹងអញ្ចឹងទៅ!!

កៈ ចាំ!!

ខៈ និយាយអោយតែគេល្អអត់សូវស្ដាប់អញ្ចឹងហាំ!!

កៈ ចាំអញ្ចឹងអរគុណ!!

ខៈ ក្មួយញ៉ុមហ្នឹងអញ្ចឹងរាល់ថ្ងៃ
កូនញ៉ុមអីក៏ដោយអោយតែនឹកឃើញតែអនាគតទៅអោយវាដើរតាមម្ដាយ!!

កៈ ចាំ!!

ខៈ ចូលសាសនាល្អចូល!!

កៈ ហ៊ឺ!!
អ៊ូភ្លេចសួរមួយមីងម៉េចដែរមុនដំបូងម៉េចបានជ្រើសរើសផ្លាស់ប្ដូរសាសនាហ្នំ!!តើតាមរយៈសាសនាគ្រីស្ដបានផ្លាស់ប្ដូរជីវិតអ្នកមីងម៉េចដែរ?

ខៈ ហ្នឹងតាមយោបល់ញ៉ុមទេណាស់ តាមរយៈសាសនាណាក៏ល្អដូចតែគ្នាហ្នឹង
តែគ្រាន់តែថាញ៉ុមសាសនាគ្រីស្ដញ៉ុមចង់ចូលដើម្បីដូចថាសាសនាល្អ សាសនាគ្រីស្ដល្អ។

កៈ ចាំ!!

ខៈ គេបង្រៀនយើងអោយយើងចេះដឹង បង្រៀនយើងពីអាក្រក់ទៅល្អ ទៅល្អ
អោយធ្វើមនុស្សល្អ!! ហើយសាសនាល្អបង្រៀនអោយយើងល្អ ហើយហ្នឹង
ចាំមើលខ្ញុំពេលមុនដំបូងហាំឃើញញ៉ុមឃើញវិហារសាសនាយេស៊ូវហ្នឹងញ៉ុមថាអញ្ចេកហេវិហារអីគេញ៉ុមអត់ស្គាល់ហាំដំបូងហាំ!!អីគេថាអញ្ចេកអីសាសនាយេស៊ូវ
ដល់ពេលហើយទៅញ៉ុមថាអូយញ៉ុមចាំចូលអោយបានវិហារហ្នឹង វិហារតាខ្មៅហ្នឹងហាំ!!
វិហារយើងរាល់ថ្ងៃហ្នឹងហាំ!!

កៈ ចាំ!!

ខៈ ហើយពេលញ៉ុមចូលដំបូងញ៉ុមឃើញអែលឌើរសាស
ហាអែលឌើរគ្រែមគើរហើយនឹងអែលឌើរអូរសិនហាំ!!ញ៉ុមថាអញ្ចេកមើលអែលឌើរមើលជន
ជាតិអាមេរិកកាំងហ្ហ៎ ហើយហ៊ឹឈរនៅហ្នឹងធ្វើអីហ្នឹងឈរសាសនា
ហើយញ៉ុមអត់សូវចេះនិយាយទេកាលមុនណាស់
ញ៉ុមចេះតែនិយាយដូចថាយើងអត់សូវចេះនិយាយហា ញ៉ុមថាអើរមើលអែលឌើរហ្ហ៎
មើលជនជាតិអាមេរិកកាំង ញ៉ុមមិនមែននិយាយអែលឌើរទេណាស់!!

កៈ ហ៊ឹៗ!!

ខៈ ហ៊ឹមើលជនជាតិអាមេរិកកាំងហ្ហ៎!!

កៈ ហ៊ឹ!

ខៈ ញ៉ុមជិះរឺម៉ក់ហាំ!! ហើយដល់ពេលហើយទៅ
មើលជនជាតិអាមេរិកកាំងឈរពីរនាក់ហ្នឹងឈរធ្វើអីគេ ញ៉ុមនិយាយអ៊ីចឹតងណាស់!!
អើរគេថាយេស៊ូវ យេស៊ូវ ចាំមើលញ៉ុមចាំចូលហើយ
ញ៉ុមចូលអោយបានថ្ងៃណាមួយញ៉ុមចូលអោយបានសាសនាហ្នឹង
ចូលអោយបានញ៉ុមតាំងចិត្តអ៊ីចឹងណាស់!!
ញ៉ុមនឹកឃើញនៅក្នងុចិត្តទេណាស់!!ដល់ពេលហើយញ៉ុមថាអញ្ចេកទៅមកវិញទៅមើលមកវិ
ញ ញ៉ុមថាអញ្ចេកហ៊ឹចូលសាសនាហ្នឹងអោយបាន អើយ អើយ ថ្ងៃណាបានចូលទេ
ចេះតែនឹកក្នុងចិត្តអញ្ចឹងហាំ!!

កៈ ចាំ!!

ខៈ ដល់ពេលហើយថ្ងៃណាមួយចូលបាន ចូលបានមែន ញ៉ុមចូលទៅ ចូលទៅញ៉ុមចូលដំបូង
ដំបូងញ៉ុមសួរបងម៉ារី ញ៉ុមថាហ៊ឹបងញ៉ុមចង់ចូលសាសនាហ្នឹង
បងម៉ារីហ្នឹងអត់ដែលឃើញមកទេឥឡូវហ្នឹងហាំ!! ចូលជាមួយមីងគឹមហាក់ហាំ!!
តែឥឡូវបងម៉ារីអត់ដែលឃើញគាត់ ហ្នឹងហើយបងម៉ារី ឈ្មោះមីងម៉ារី ម៉ារីនោះ!!
ហ្នឹងញ៉ុមចូលសួរគាត់មុនគេហ្នឹង!!

កៈ ចាំ!!

ខ៖ ញ៉ុមថាអញ្ចេកហ៊ីមីងញ៉ុមចង់ចូលសាសនាហ្នឹង អូយចូលទៅមីអូន
!!ដល់ហើយគាត់ថាអញ្ចេកណោះអ៊ែលឌើរ អ៊ែលឌើរពីរនាក់ហ្នឹងឈរចាំទទួលហ្នំ!!
ដល់ពេលហើយគាត់នាំញ៉ុមមក ញ៉ុមមកហើយញ៉ុមចូលទៅ។

ក៖ អ៊ីចឹងនៅកោះគរមីងដំបូងគេហោ?

ខ៖ ចាំ!!ហ្នឹង ដល់ពេលហើយជួបអ៊ែលឌើរត្រែបភើរ
អើរអ៊ែលឌើរត្រែបភើរហើយហ្នឹងអ៊ែលឌើរអូរសិន
ញ៉ុមនិយាយជាមួយនឹងអ៊ែលឌើរត្រែបភើរហើយនឹងអ៊ែលឌើរអូរសិនហ្នឹងដល់ពេលហើយបាន
ចូលទៅដល់ពេលហើយញ៉ុមបានអើរផ្សព្វផ្សាយនៅ!!

ក៖ អ្នកភូមិណោះ!!

ខ៖ អ្នកនៅជិតហ្នឹង ហ្នឹងហើយ គ្រាន់តែចូលជាង២០នាក់ជាមួយញ៉ុមហាំ!!ក៖ ចាំ!ខ៖ ហ្នឹង!!

ក៖ តែក៏គាត់ខ្លះអត់បានទៅជាប់អញ្ចឹងទៅណាស់!!ចាំ!!

ខ៖
ស្រាប់ដល់ពេលហើយទៅញ៉ុមចូលទៅបានដូចសេចក្ដីប្រាថ្នាញ៉ុមទៅ!!ដល់ពេលតែគ្រាន់តែ
ថាឥឡូវញ៉ុមអសកម្មអញ្ចេកញ៉ុមសូវបានទៅវិហារដោយសារអាកុងញ៉ុមហ្នឹងចេះតែ!!

ក៖ រករឿង។

ខ៖ រករឿង អញ្ចឹងបានថា
អញ្ចឹងបានថាអញ្ចេកញ៉ុមទៅខ្លះខានខ្លះអញ្ចឹងទៅណាស់!!ទំរាំតែគាត់ទៅស្រុកទៅញ៉ុមបានធូ
រ ញ៉ុមបានទៅជាប់។

ក៖ ចាំហ្នឹងហើយ!!

ខ៖ អ៊ីចឹងបានថាញ៉ុមពិបាកកូនញ៉ុមរាល់ថ្ងៃ!!

ក៖ ចាំហ្នឹងហើយ អញ្ចឹងអរគុណច្រើនអ្នកមីងសំរាប់ការសំភាសន៍ពីជីវិតដ៏ក្បោះក្បាយ!!

ខ៖ ញ៉ុមអត់ដឹងខុសត្រូវទេ!!

ក៖  ត្រូវហើយ ជីវិតរបស់មីងតើ!!!

ខ៖  ខ្លាចតែកូនទេ ញ៉ុមនឹកថាតែនេះទេញ៉ុមចេះតែនិយាយទៅ!

ក៖  ចាំអញ្ចឹងអរគុណណាស់អ្នកមីង!!

ខ៖  ព្រោះអីញ៉ុមអត់ស្កូវចេះអក្សរញ៉ុមចេះតែនិយាយទៅ!!

ក៖  ចាំហ្នឹងហើយអត់ទេ !!

ខ៖ ហ្នឹង!!

ក៖  ដោយសារមួយហ្នឹងជាជីវិតមិនមែនខុសមិនមែនត្រូវអីទេអ្នកមីង!!

ខ៖  អញ្ចឹង!!

ក៖  ចាំអរគុណមីង។